ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនផ៉ាក

CAMPU LONPAC INSURANCE 柬捕寨大众伦平保险

# យើងខ្ញុំធានារ៉ាប់រងលោកអ្នក ក្នុងប្រទេសកម្ពុជា

## កិច្ចសន្យាធានារ៉ាប់រងលើភោជនីយដ្ឋាន

ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាសរសេរលិខិតមកក្រុមទទួលពាក្យបណ្តឹងរបស់យើងខ្ញុំ :

| | | |
|---|---|---|
| អាសយដ្ឋានទំនាក់ទំនង | : | **ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី** |
| | | ជាន់ទី៧ នៃអគារកម្ពុបែង |
| | | ផ្ទះលេខ ២៣ ផ្លូវ ១១៤ |
| | | សង្កាត់ផ្សារថ្មី ២ |
| | | ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| | | ព្រះរាជាណាចក្រកម្ពុជា |
| | | ប្រអប់សំបុត្រ ១៥៥៦ |
| លេខទូរស័ព្ទ | : | + ៨៥៥ ២៣ ៩៦៦ ៩៦៦ / ៩៩៨ ២០០ / ៩៨៦ ២៧៩ |
| លេខទូរសារ | : | + ៨៥៥ ២៣ ៩៨៦ ៣០៨ / ២៧៣ |
| អ៊ីមែល | : | complaint@campulonpac.com.kh |
| គេហទំព័រ | : | www.campulonpac.com.kh |

**ក្នុងករណីមានឧប្បត្តិហេតុកើតឡើង**

**លេខទូរសព្ទ័ប្រចាំការ២៤ម៉ោង**

+ ៨៥៥ ១៦ ៨១០ ៩៩៩ / ៨២០ ៩៩៩

+ ៨៥៥ ១៧ ៧៩៩ ៩០២ / ៧៩៩ ៩០៣

អ៊ីមែល : claims@campulonpac.com.kh

សំគាល់:

ក្នុងករណីមានវិវាទកើតឡើង ឬការខុសឆ្គងអត្ថន័យណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ នោះក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំនឹងយកកិច្ចសន្យាធានារ៉ាប់រងជាភាសាអង់គ្លេសជាសំអាង ។
យើងខ្ញុំសូមស្នើជាពិសេសថា សូមលោកអ្នកអានកិច្ចសន្យាធានារ៉ាប់រងនេះអោយបានហ្មត់ចត់និងផ្ញើត្រឡប់មកកាន់ក្រុមហ៊ុនយើងខ្ញុំវិញភ្លាមប្រសិនបើមានភាពចាំបាច់ត្រូវកែតម្រូវ ។

## កិច្ចសន្យាធានារ៉ាប់រងលើគេហដ្ឋានលំនៅឋាន

**ដោយហេតុថា** បុគ្គលដែលត្រូវបានធានារ៉ាប់រងដូចមានឈ្មោះនៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យានេះ ដែលតាមរយៈទំរង់បែបបទស្នើសុំការធានារ៉ាប់រង និងសេចក្ដីប្រកាសអះអាង ដែលនឹងត្រូវក្លាយជាធាតុសំខាន់ និងជាមូលដ្ឋានគ្រឹះនៃកិច្ចសន្យានេះ បានស្នើសុំការធានារ៉ាប់រងពី ក្រុមហ៊ុនធានារ៉ាប់រង កម្ពុជាវៀតណាម ភីអិលស៊ី (តទៅនេះហៅកាត់ថា ក្រុមហ៊ុន) និងបានបង់ ឬយល់ព្រមបង់នូវបុព្វលាភធានារ៉ាប់រងដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធសំរាប់កិច្ចសន្យាធានារ៉ាប់រងនេះ ។

**ដោយហេតុនេះ កិច្ចសន្យានេះផ្តល់នូវសក្ខីកម្មដែលបញ្ជាក់ថា** ក្នុងករណីមានហេតុការណ៍កើតឡើងក្នុងអំឡុងពេលធានារ៉ាប់រង ដូចដែលបានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ និងដោយគោរពតាម ខចែង ករណីលើកលែង និងលក្ខខណ្ឌផ្សេងៗដែលមានក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ឬនៅក្នុងបដិលេខ (តទៅត្រូវបានចាត់ទុកថាជាលក្ខខណ្ឌនៃកិច្ចសន្យានេះ) ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងទៅតាមលក្ខណៈ និងទំហំនៃការខូចខាត ដែលបានផ្តល់ជូននៅក្នុងផ្នែកនីមួយៗ ។

## ផ្នែកទី ១ (ក) អគ្គិភ័យ និងហានិភ័យផ្សេងៗ

**និយមន័យ**

ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង មានន័យថាជាទ្រព្យសម្បត្តិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬជាទ្រព្យសម្បត្តិដែលត្រូវទទួលខុសត្រូវដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ដូចជា :

i. អគារ និងអគារផ្សេងៗទៀតដែលស្ថិតនៅក្នុងបរិវេណតែមួយ (ប្រសិនបើមានការធានាជាក់លាក់ណាមួយ) ដោយមិនរាប់បញ្ចូលអំពីគ្រឹះនៃអគារ
ii. សន្ទិធិ
iii. គ្រឿងសង្ហារិម, សេនាសនភណ្ឌ, របស់របរដែលជាប់នឹងអគារ, ការតែងលំអ ឬការធ្វើអោយប្រសើរឡើង ទោះបីជាធ្វើឡើងដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬជាកម្មសិទ្ធិរបស់ម្ចាស់អគារដែលជាការទទួលខុសត្រូវរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង
iv. សម្ភារការិយាល័យដូចជា កុំព្យូទ័រ, ឯកសារកម្មសិទ្ធិផ្សេងៗ, ឯកសារ និងប៉ាន់គំរូរបស់ទំនិញផ្សេងៗ និង
v. ការតែងលំអ ឬការធ្វើអោយប្រសើរឡើងដែលបានធ្វើឡើងដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ព្រមទាំងសម្ភាររបស់ម្ចាស់អគារដែលមានជាប់នឹងអគារ ។

**ការទទួលខុសត្រូវ**

តាមសម្រេចចិត្តរបស់ខ្លួន ក្រុមហ៊ុននឹងជួសជុលអោយដូចដើមវិញ ឬផ្លាស់ចេញនូវទ្រព្យសម្បត្តិដែលខូចខាត ជូនចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងរហូតដល់ចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ពន្ធ័នៅក្នុងអំឡុងពេលធានារ៉ាប់រងណាមួយ ចំពោះការបាត់បង់ ឬខូចខាតលើទ្រព្យសម្បត្តិដែលត្រូវបាន ធានារ៉ាប់រងដែលជាហេតុបង្កឡើងដោយហានិភ័យដូចខាងក្រោម :

១. អគ្គិភ័យ ប៉ុន្តែលើកលែងករណីខូចខាត ឬបាត់បង់ដែលបង្កឡើងដោយ :
   ក) ការបាត់បង់ដោយអំពើចោរកម្ម នៅក្នុងពេល ឬក្រោយពេលមានអគ្គិភ័យ
   ខ) ការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិដែលបណ្តាលមកពីការឡើងមេដោយខ្លួនឯង (it own fermentation) ការឡើងកម្តៅដោយធម្មជាតិឬការឆេះដោយឯកឯង ឬដោយសារការទទួលរងកម្តៅដោយឯកឯង ឬដំណើរការសម្ងួត
   គ) អគ្គិភ័យក្រោមដី
   ឃ) ការដុតទ្រព្យសម្បត្តិ តាមបទបញ្ជារបស់អាជ្ញាធរសាធារណៈ ។
២. រន្ទះ
៣. ការបែកធ្លាយនិងការហៀរចេញនៃទឹកពីធុងដាក់ទឹក,ឧបករណ៍ឬបំពង់បង្ហូរទឹកដែលនៅជាប់នឹងអគារដែលជាទ្រព្យសម្បត្តិត្រូវបានធានារ៉ាប់រងប៉ុន្តែលើកលែងនូវករណីដូចខាងក្រោម :
   ក) ការខូចខាតមុនពេលមានធានារ៉ាប់រង
   ខ) ការខូចខាត ឬការបាត់បង់ខណៈពេលដែលអគារត្រូវបានទុកចោលដោយគ្មានការថែទាំ
   គ) ការខូចខាត ឬការបាត់បង់ដែលបណ្តាលមកពីការស្រុត ឬបំណាក់ស្រុតដី
   ឃ) ការខូចខាត ឬការបាត់បង់ដែលបណ្តាលមកពីទឹកធ្លាយ ឬលេចចេញពីឧបករណ៍ពន្លត់អគ្គិភ័យដែលដំណើរការដោយស្វ័យប្រវត្តិ ដែលបានតំឡើងជាប់នឹងអគារ
   ង) ចំនួនទឹកប្រាក់ដំបូង (ចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាធានារ៉ាប់រង) សំរាប់បណ្តឹងទាមទារសំណងនីមួយៗ ។

៤. ព្យុះភ្លៀង និងព្យុះសង្ឃរា ដែលមានន័យថាការខូចខាត ឬការបាត់បង់ដែលបង្កឡើងដោយផ្ទាល់ដោយសារអគ្គិភ័យ ឬបើមិនដូច្នោះទេបង្កឡើងដោយ ឬតាមរយៈ ឬពាក់ព័ន្ធនឹងខ្យល់ព្យុះ, ព្យុះទីហ្វុង និងព្យុះភ្លៀង ប៉ុន្តែករណីនេះត្រូវផ្អែកលើ ខចែងស្តីពីចំនួនទឹកប្រាក់មិនធ្វើសំណង និងលក្ខខណ្ឌពិសេស ដូចខាងក្រោមៈ

**ខចែងស្តីពីចំនួនទឹកប្រាក់មិនធ្វើសំណង**

នេះគឺការព្រមព្រៀង និងឯកភាពគ្នាថា ការបាត់បង់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដែលបង្កឡើងដោយផ្ទាល់ពីព្យុះភ្លៀង និងព្យុះសង្ឃរា ការទទួលខុសត្រូវរបស់ក្រុមហ៊ុនត្រូវបានកំណត់ចំពោះចំនួនទឹកប្រាក់ ដែលការខូចខាត ឬការបាត់បង់នោះលើសពីចំនួនទឹកប្រាក់ដំបូង (ចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ) សំរាប់រាល់បណ្តឹងទាមទារសំណងនីមួយៗ ។

ជាងនេះទៅទៀតការព្រមព្រៀងចំពោះ ខចែងនេះនឹងអនុវត្តដាច់ដោយឡែកចំពោះ :

(i) ក្នុងគោលបំណងនេះ ទ្រព្យសម្បត្តិនីមួយៗ ដែលត្រូវបានដាក់ធានាស្ថិតនៅក្នុងទីតាំងដូចគ្នា ត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិតែមួយ

(ii) គ្រោះថ្នាក់នីមួយៗដែលបណ្តាលអោយមានការបាត់បង់ ឬការខូចខាតដែលសំរាប់គោលបំណងនេះ គ្រោះថ្នាក់នោះមិនត្រូវបានចាត់ទុកថាត្រូវបានបញ្ចប់នោះទេ រហូតដល់រយៈពេល ៧ ថ្ងៃបន្តបន្ទាប់គ្នាដោយមិនជាប់ពាក់ពន្ធ័នឹងហានិភ័យផ្សេងទៀត ហើយក្នុងករណីនេះ ខចែងនេះនឹងត្រូវអនុវត្តសារជាថ្មី ។

**លក្ខខណ្ឌពិសេស**

១. ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីទឹក ឬទឹកភ្លៀង ទោះបីបង្កឡើងដោយខ្យល់ ឬមិនមែនក្តី លែកលែងតែអគារ ឬទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ទទួលរងការខូចខាតផ្នែកដំបូល ឬជញ្ជាំងជាក់ស្តែងជាមុនសិន ដែលបង្កឡើងដោយផ្ទាល់ពីព្យុះសង្ឃរា, ព្យុះទីហ្វុង, ព្យុះស៊ីក្លូន និងព្យុះភ្លៀង ក្នុងករណីនេះក្រុមហ៊ុននឹងទទួលខុសត្រូវចំពោះការខូចខាតផ្នែកខាងក្នុងនៃអគារឬទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដែលអាចបណ្តាលមកពីទឹក ឬទឹកភ្លៀងចូលទៅក្នុងអគារតាមរយៈការរបើកដំបូល ឬជញ្ជាំងដែលបង្កឡើងដោយផ្ទាល់ពីហានិភ័យដែលបានរៀបរាប់ខាងលើ ។

២. បដ្ឋិលេខនេះមិនទទួលខុសត្រូវចំពោះការធានារ៉ាប់រងដូចខាងក្រោម :

ក. ការខាតបង់ផ្នែកហិរញ្ញវត្ថុតាមគ្រប់រូបភាព ។

ខ. ការខូចខាត ឬការបាត់បង់ដែលបណ្តាលមកពីការធ្លាក់ព្រិល ទោះបីជាបង្កឡើងដោយខ្យល់ ឬមិនមែនក្តី ។

គ. ការខូចខាត ឬការបាត់បង់ដែលបណ្តាលមកពីការស្រុត ឬបំណាក់ស្រុតដី លែកលែងតែក្នុងករណីបង្កឡើងដោយគ្រោះរញ្ជួយផែនដី ឬ បន្ទុះភ្នំភ្លើង ក្នុងលក្ខខណ្ឌដែលហានិភ័យទាំងនេះត្រូវបានធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះ ។

ឃ. ការបាត់បង់ ឬការខូចខាតដែលបង្កឡើងដោយសារការផ្ទុះផ្សេងៗ លែកលែងតែការបាត់បង់ ឬការខូចខាតដោយសារការផ្ទុះកំស្ស៊ៀវ (Domestic Boiler) ប្រើក្នុងផ្ទះ និងធុងហ្គាសដែលប្រើសម្រាប់គោលបំណងបំភ្លឺ ឬគោលបំណងប្រចាំថ្ងៃក្នុងផ្ទះ ដែលហ្គាសមិនត្រូវបានផលិត និងដែលមិនបង្កើតបានជាផ្នែកមួយនៃការងារហ្គាស នឹងត្រូវចាត់ទុកថាជាការបាត់បង់ដោយសារអគ្គិភ័យ នៅក្នុងវិសាលភាពនៃអត្ថន័យនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ។

ង. ការខូចខាតដែលបណ្តាលមកពីហេតុផលនៃបទបញ្ញត្តិ ឬច្បាប់សាងសង់ ឬជួសជុលអគារ ។

៣. ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាត នៅពេលដែលការបាត់បង់ ឬការខូចខាតនោះកើតឡើងត្រូវបានធានារ៉ាប់រងដោយ ឬក្នុងករណីមានអត្ថិភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបានធានារ៉ាប់រងដោយកិច្ចសន្យាធានារ៉ាប់រងផ្សេងៗទៀត លើកលែងតែពាក់ព័ន្ធនឹងការលើសកំណត់ហួសបរិមាណទឹកប្រាក់ដែលនឹងត្រូវបង់ស្របតាមកិច្ចសន្យាធានារ៉ាប់រងនោះ ឬកិច្ចសន្យាធានារ៉ាប់រងផ្សេងៗទៀតដែលមិនធ្វើអោយការធានារ៉ាប់រងនេះមានសុពលភាព ។

៤. លែកលែងតែមានការបញ្ជាក់ជាពិសេស និងមានការធានារ៉ាប់រងដាច់ដោយឡែក បដ្ឋិលេខនេះមិនទទួលខុសត្រូវលើ :

ក. បំពង់លោហធាតុសំរាប់បញ្ចេញផ្សែង, រនាំងបាំងសាច (សំរាប់ដាក់លើទ្វារ ឬបង្អួច), ព្រិលបង្អួច, ស្លាកសញ្ញា និងសម្ភារផ្សេងៗទៀតដែលនៅជាប់នឹងអគារផ្នែកខាងក្រៅ ។

ខ. បរិវេណខាងក្រៅក្នុងខណៈពេលកំពុងសាងសង់, ការជួសជុល ឬសាងសង់ឡើងវិញ លើកលែងតែផ្នែកខាងក្រៅនៃទ្វារ, បង្អួច និងផ្នែកផ្សេងទៀតដែលអាចបើកបានត្រូវបានធ្វើរួចរាល់ និងការពារចំពោះព្យុះសង្ឃរា, ព្យុះស៊ីក្លូន, ព្យុះទីហ្វុង និងព្យុះភ្លៀង ក្នុងករណីដែលហានិភ័យទាំងនោះត្រូវបានធានាដោយកិច្ចសន្យាធានរ៉ាប់រងនេះ ។

ត្រូវអនុវត្តរាល់ ខចែង និងលក្ខខណ្ឌទាំងអស់ដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ

**ការធានារ៉ាប់រងបន្ថែម**

១. ការផ្លាស់ប្តូរ ឬការជួសជុល

កម្មករនិយោជិតត្រូវបានអនុញ្ញាតអោយចេញ ឬចូលក្នុងបរិវេណអគារ ដើម្បីធ្វើការផ្លាស់ប្តូរ ឬជួសជុលតូចតាចដោយមិនចាំបាច់អនុវត្តនូវលក្ខខណ្ឌនៃកិច្ចសន្យានេះ ។

២. ការវាយតម្លៃ

ប្រសិនបើបណ្តឹងទាមទារសំណងជារួមសំរាប់ករណីបាត់បង់នីមួយៗ មិនលើសពី ១.000 ដុល្លារ ឬ ៥% នៃចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងដោយយកចំនួនណាមួយដែលតិចជាងគេ សំរាប់ការខូចខាតទ្រព្យសម្បត្តិមួយ ឬច្រើន នោះក្រុមហ៊ុនមិនតម្រូវអោយប្រគល់ជូនក្រុមហ៊ុននូវបញ្ជី សារពើភ័ណ្ឌ ឬការវាយតម្លៃចំពោះទ្រព្យសម្បត្តិដែលមិនមានការខូចខាតឡើយ ។

៣. ថ្លៃសេវាកងកំលាំងពន្លត់អគ្គិភ័យ និងថ្លៃផ្លាស់ឧបករណ៍ពន្លត់អគ្គិភ័យ

ការធានារ៉ាប់រងស្ថិតនៅក្នុងផ្នែកនេះរួមបញ្ចូលទាំងថ្លៃសេវាកងពន្លត់អគ្គិភ័យ និងថ្លៃបំពេញឡើងវិញសំរាប់ឧបករណ៍ពន្លត់អគ្គិភ័យ ដោយការទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះថ្លៃចំណាយទាំងនោះ នឹងត្រូវបានកំនត់ចំពោះករណីពិសេស នឹងសមហេតុផលដែលបានកើតឡើងក្នុងការពន្លត់អគ្គិភ័យដែលស្ថិតនៅទីតាំង ឬនៅជិតទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងដោយកិច្ចសន្យានេះ ឬទទួលការគំរាមកំហែងភ្លាមៗពីអគ្គិភ័យ ចំពោះទ្រព្យសម្បត្តិទាំងនោះ ប៉ុន្តែការចំណាយទាំងនោះមិនត្រូវលើសពីចំនួនទឹកប្រាក់ ៥00 ដុល្លារ សំរាប់ករណីបាត់បង់នីមួយៗឡើយ ។

៤. ការធានារ៉ាប់រងបន្ថែមផ្សេងទៀត

វាគឺជាការព្រមព្រៀងគ្នាដែលថា ពាក្យ "ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង" រួមបញ្ចូលផងដែរនូវ :

ក) ឯកសារផ្សេងៗ ឯកសារសរសេរដោយដៃ និងសៀវភៅអាជីវកម្ម ប៉ុន្តែសម្រាប់តែតម្លៃសម្ភារការិយាល័យរួមទាំងថ្លៃចំណាយ សម្រាប់បុគ្គលិកក្នុងការសរសេររៀបចំ និងមិនមែនជាតម្លៃដែលត្រូវបានធានារ៉ាប់រង ហើយដែលតម្លៃនោះមិនត្រូវលើសពីចំនួនទឹកប្រាក់ ២៥0 ដុល្លារ សម្រាប់ឯកសារនីមួយៗ ឯកសារសរសេរដោយដៃ ឬសៀវភៅអាជីវកម្ម ។

ខ) កំណត់ត្រាដោយប្រពន្ធ័កុំព្យូទ័រ ប៉ុន្តែសម្រាប់តែតម្លៃសម្ភាររួមទាំងថ្លៃចំណាយសំរាប់បុគ្គលិក និងការចំណាយលើពេលវេលារបស់កុំព្យូទ័រក្នុងការបោះពុម្ពកំណត់ត្រាឡើងវិញ (លើកលែងការចំណាយផ្សេងៗ ដែលពាក់ពន្ធ័នឹងការបង្កើតនូវព័ត៌មានដែលត្រូវបានកត់ត្រាក្នុងប្រព័ន្ធកុំព្យូរទ័រ) ហើយដែលតម្លៃនោះមិនត្រូវបានកំណត់នៅក្នុងចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងដែលមាននៅក្នុងកិច្ចសន្យានេះ ដោយការចំណាយនោះមិនត្រូវលើសពីចំនួនទឹកប្រាក់ ២៥0 ដុល្លារ ឡើយ ។

គ គំនូរ, ប៉ាន់គំរូ, ពុម្ព, ប្លង់ ឬគម្រោងផ្សេងៗដែលមានតម្លៃមិនលើសពីចំនួនទឹកប្រាក់ ២៥0 ដុល្លារសម្រាប់គំនូរ, ប៉ាន់គំរូ, ពុម្ព ឬគម្រោងនីមួយៗ ។

៥. ការដឹកជញ្ជូនចេញនូវកាកសំណល់

ការធានារ៉ាប់រងស្ថិតនៅក្នុងផ្នែកបន្ថែមនេះ រួមបញ្ចូលផងដែរនូវថ្លៃ និងការចំណាយផ្សេងៗដែលកើតមានឡើងជាចាំបាច់ សំរាប់បុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងការរើចេញ ឬបោះចោលនូវកាកសំណល់, ការរុះរើ និងការវាយកំទេចចោល និងការធ្វើទម្រ ឬជន្ទល់ទ្រូសម្រាប់ការជួសជុលបណ្តោះអាសន្ននៃផ្នែកណាមួយ ឬផ្នែកផ្សេងទៀតនៃទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដោយថ្លៃ ឬការចំណាយទាំងនោះ

ក) មិនអាចទទួលបានការធ្វើសំណងពីកិច្ចសន្យាធានារ៉ាប់រងផ្សេងៗទៀត

ខ) មិនត្រូវបានរាប់បញ្ចូលនូវថ្លៃផ្លាស់ប្តូរទីតាំង,ថ្លៃសម្អាត ឬថ្លៃរើចេញនូវសារធាតុដែលបង្កអោយមានជាតិពុល ឬការចម្លងរោគ ។

គ) មិនត្រូវលើសពីចំនួន ៥% នៃតម្លៃធានារ៉ាប់រងសរុប ដោយផ្អែកតាមផ្នែកខាងលើនេះ ។

## ករណីលើកលែង

ការធានារ៉ាប់រងក្នុងផ្នែកនេះមិនទទួលខុសត្រូវលើ :

១. ទ្រព្យសម្បត្តិ (លើកលែងស្លាកសញ្ញា ឬស្លាកសញ្ញាធ្វើពីណេអុង) ស្ថិតនៅក្នុងទីលំហ ឬខណៈពេលដែលកំពុងសាងសង់, កសាង, តំឡើង, ជួសជុលថែទាំ, រុះរើ, ការវាយកំទេច, ការផ្លាស់ប្តូរទីតាំង ឬការសាកល្បងផ្សេងៗ ។

២. ខណៈពេលដែលទ្រព្យសម្បត្តិស្ថិតនៅក្នុងសង្វាក់ផលិតកម្ម ប្រសិនបើការបាត់បង់, ការបំផ្លាញ, ឬការខូចខាតកើតមានក្នុងពេលដែលទ្រព្យសម្បត្តិបាននឹងកំពុងប្រតិបត្តិការជាក់ស្តែង ។

៣. រោមសត្វ, សំលៀកបំពាក់ដែលតែងលំអដោយរោមសត្វ, គ្រឿងអលង្ការ, នាឡិកា, គុជខ្យង, ផ្នែកទាំងមូល ឬផ្នែកណាមួយនៃត្បូងពេជ្រមានតម្លៃ, មាស, ប្រាក់, ប្លាកទីន ឬលោហធាតុមានតម្លៃ និងលោហធាតុផ្សំផ្សេងៗទៀត ។

៤. សត្វចិញ្ចឹម, បក្សី, ត្រី ឬរុក្ខជាតិផ្សេងៗ ។

៥. (ក) ការបាត់បង់ផ្នែកហិរញ្ញវត្ថុតាមគ្រប់រូបភាព

(ខ) ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីការខូចខាតបន្តិចម្តងៗ, គុណវិបត្តិដែលជាប់ជាមួយ, អនិបុណភាពដែលមិនអាចមើលឃើញ, សត្វល្អិតគ្រប់ប្រភេទ, រេណុប្បត្តសត្វ (ប្រភេទមេអំបៅម្យ៉ាង), សត្វល្អិតចង្រៃ, កណ្តៀរ, ការចម្លងរោគផ្សេងៗ, សំណើករេចរឹល, ភាពសើម ឬស្ងួតនៃបរិយាកាស, សីតុណ្ហភាពប្រែប្រួល ឬការឡើងកម្តៅខ្លាំង, ការធ្វើអោយកខ្វក់បរិយាកាស, ការបាត់បង់បរិមាណ ឬតម្លៃ, ការបង្ហួត,

ការបាត់បង់ទម្ងន់, ច្រែះ, ដំណើរខូចខាតដែលបណ្តាលមកពីសំណើម ឬសម្ងួត, ការខូចខាតដែលបណ្តាលមកពីដំណើរច្រែះស៊ី, ការប្រែប្រួលរសជាតិ ឬពណ៌ ឬវាយនភណ្ឌ ឬផលិតផលសម្រេច ឬសកម្មភាពនៃពន្លឺ ។

(គ) ការខូចខាតដែលកើតឡើងដោយមិនអាចពន្យល់បកស្រាយបាន ឬការបាត់បង់ដោយអាថ៌កំបាំង ឬការខ្វះខាតផ្នែកសន្និធិត្រូវបានរកឃើញតាមរយៈបញ្ជីសារពើភ័ណ្ឌ ។

(ឃ) ការបាត់បង់ណាមួយដែលកើតឡើងដោយសារការក្លែងបន្លំ ឬដោយភាពមិនស្មោះត្រង់របស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬសមាជិក គ្រួសារណាមួយ ឬអ្នកនៅក្នុងបន្ទុករបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬអគ្គនាយក, អ្នកចូលហ៊ុន ឬនិយោជិតរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

(ង) ការចំណាយចំពោះការផ្លាស់ប្តូរ ឬការកែតម្រូវសម្ភារ, ទឹកដៃ, ប្លង់ ឬអនិបុណភាព ឬការខ្វះចន្លោះនៅក្នុងប្លង់, គម្រោង ឬសេចក្តីលម្អិតផ្សេងៗ ។

(ច) ការបង្អក ឬកំណកនៃសម្ភាររលាយ ។

(ឆ) ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីការបង្ខំអោយអនុវត្តលក្ខន្តិកៈ ឬបទបញ្ជាសំរាប់គ្រប់គ្រងការដ្ឋានសំណង់, ការជួសជុល ឬការវាយកំទេចក្នុងបរិវេណអគាររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងដោយការបញ្ឈប់ជាបណ្តោះអាសន្ន, អស់អាយុកាល ឬការមោឃភាពនៃកិច្ចសន្យាជួលណាមួយ ឬបទបញ្ជាផ្សេងៗ ។

៦. (ក) ការខូចខាតផ្នែកប្រព័ន្ធអគ្គិសនី ឬប្រព័ន្ធមេកានិច ឬដំណើរការមិនប្រក្រតីនៃគ្រឿងម៉ាស៊ីន ឬឧបករណ៍ផ្សេងទៀត ។

(ខ) ការខូចខាតចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដោយសារការប្រែប្រួលសីតុណ្ហភាព ឬសំណើម ឬការមិនដំណើរការ ឬប្រតិបត្តិមិនប្រក្រតីនៃម៉ាស៊ីនត្រជាក់, ប្រព័ន្ធកម្តៅ ឬប្រព័ន្ធត្រជាក់ ។

(គ) បម្រែបម្រួលផែនដី, ចលនាពើងដី, បំណាក់ស្រុតដី, សំណឹក, ស្នាមប្រេះ ។

៧. ប្រាក់កាស, ប័ណ្ណភាគហ៊ុន ឬឧបករណ៍ដែលអាចលក់បាន, សំបុត្រធ្វើដំណើរ, លើកលែងតែមានការបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ឬទ្រព្យសម្បត្តិ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាត្រូវបានដាក់ធានារ៉ាប់រង ។

៨. ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពី ឬកើតឡើងពីការធ្វើកម្មវិធី, ការជាប់សោរ, ការបិទស្លាក ឬការបញ្ចូល ឬការលុបព័ត៌មានដោយសារការធ្វេសប្រហែស ឬការលុបចោលទិន្នន័យព័ត៌មាន និងការបាត់បង់ព័ត៌មានដែលបណ្តាលមកពីដែនម៉ាញ៉េទិច ។

៩. ការបាត់បង់ ឬការខូចខាតចំពោះសន្និធិ ក្នុងខណៈពេលដែលកំពុងដឹកជញ្ជូន ។

១០. ការបាត់បង់ដែលបណ្តាលមកពីភាពកខ្វក់ ឬការចម្លងរោគ ។

## ផ្នែកទី ១ (ខ) គ្រោះថ្នាក់ចំពោះនិយោជិត

**ការទទួលខុសត្រូវ**

ក្រុមហ៊ុននឹងធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬអ្នកតំណាងស្របច្បាប់នូវអត្ថប្រយោជន៍ដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ប្រសិនបើក្នុងរយៈពេលនៃការធានារ៉ាប់រង បុគ្គលដែលត្រូវបានធានារ៉ាប់រងដែលមានអាយុចាប់ពី ១៦ឆ្នាំ ដល់ ៦៥ឆ្នាំ បានទទួលរងរបួសលើរាងកាយដែលបង្កឡើងទាំងស្រុង និងដោយផ្ទាល់ដោយសារកត្តាគ្រោះថ្នាក់ពីខាងក្រៅ និងដែលមើលឃើញនឹងភ្នែក និងជាមូលហេតុតែមួយគត់ និងដោយផ្ទាល់នៃការស្លាប់ ឬពិការភាព ជាអចិន្ត្រៃយ៍ ដែលកើតឡើងគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជាក្នុងរយៈពេល ១២ខែបន្តបន្ទាប់គ្នា ក្រោយកាលបរិច្ឆេទរងរបួសលើរាងកាយ ។

**និយមន័យ**

១. " ពិការភាពជាអចិន្ត្រៃយ៍ " មានន័យថាជាការបាត់បង់នូវការប្រើប្រាស់ទាំងស្រុង និងដែលមិនអាចជាសះស្បើយបាននៃផ្នែកអវយវៈណាមួយ ឬផ្នែកដទៃផ្សេងទៀត ដែលមានបញ្ជាក់នៅក្នុងតារាងមូលដ្ឋាននៃការធ្វើសំណង ។

២. " ការបាត់បង់ចក្ខុប្រសាទ " មានន័យថាជាការបាត់បង់នូវរបកគំហើញទាំងស្រុង និងដែលមិនអាចជាសះស្បើយបាន ។

## ផ្នែកទី ២ (ក) ការទទួលខុសត្រូវជាសាធារណៈ

**ការធ្វើសំណង**

ក្រុមហ៊ុននឹងធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង នូវចំនួនទឹកប្រាក់ទាំងអស់ដែលបុគ្គលត្រូវបានធានារ៉ាប់រង ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលទាក់ទងនឹងគ្រោះថ្នាក់ដែលបណ្តាលអោយរបួសលើរាងកាយ (រាប់បញ្ចូលទាំងការស្លាប់ ឬជំងឺ) ដែលកើតឡើងចំពោះបុគ្គលណាមួយ និងគ្រោះថ្នាក់ដែលបណ្តាលអោយបាត់បង់ ឬខូចខាតចំពោះទ្រព្យសម្បត្តិដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំរាប់រយៈពេលនៃការធានារ៉ាប់រងដែលជាប់ទាក់ទងនឹងអាជីវកម្មដូចមានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ ។

**និយមន័យ**

បុគ្គលខាងក្រោមនេះ ត្រូវបានចាត់ទុកថាជាបុគ្គលដែលត្រូវបានធានារ៉ាប់រង :

១. ឈ្មោះដែលត្រូវបានធានារ៉ាប់រង

២. អគ្គនាយក, អ្នកចូលហ៊ុន ឬនិយោជិតរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ប៉ុន្តែត្រូវបានកំណត់ក្នុងខណៈពេលដែលត្រូវបំពេញការងារតាមករណីយកិច្ចរបស់ពួកគេតែប៉ុណ្ណោះ ។

៣. នៅពេលដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងមានភាគីលើសពីមួយ នោះភាគីនីមួយៗនឹងត្រូវបានចាត់ទុកថាជាអង្គភាពដាច់ដោយឡែក និងផ្សេងៗពីគ្នា ហើយពាក្យថា " បុគ្គលដែលត្រូវបានធានារ៉ាប់រង " នឹងត្រូវបានចាត់ទុកថាបានអនុវត្តចំពោះភាគីនីមួយៗនៅក្នុងលក្ខខណ្ឌដូចគ្នា ប្រសិនបើកិច្ចសន្យាធានារ៉ាប់រងផ្សេងគ្នាត្រូវបានចេញសំរាប់ភាគីនីមួយៗ ដោយហេតុថានៅក្នុងខចែងនេះនឹងមិនបង្កើននូវការទទួលខុសត្រូវរបស់ក្រុមហ៊ុននោះទេ ។

**ដែនកំណត់នៃការធ្វើសំណង**

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនសំរាប់រាល់បណ្តឹងទាមទារសំណងទាំងអស់ នឹងមិនត្រូវលើសពីដែនកំណត់នៃការធ្វើសំណង ដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ពន្ធ័សំរាប់ហេតុការណ៍មួយករណី ឬហេតុការណ៍ជាច្រើនបន្តបន្ទាប់គ្នាដែលកើតចេញពីមូលហេតុដើមតែមួយ ហើយបណ្តាលអោយបាត់បង់ ឬរងរបួសលើរាងកាយដោយមិនកំណត់ក្នុងអំឡុងពេលនៃការធានារ៉ាប់រងនីមួយៗ ក្នុងករណីដែលហេតុការណ៍ជាច្រើននោះបានកើតឡើង ។

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងករណីមានបណ្តឹងទាមទារសំណងកើតឡើង គឺស្ថិតនៅក្នុងយុត្តាធិការស្របច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាក្នុងអំឡុងពេលនៃការធានារ៉ាប់រងនីមួយៗ នឹងមិនត្រូវលើសពីដែនកំណត់នៃការធ្វើសំណងដែលមានបញ្ជាក់នៅក្នុងតារាងឧបសម្ពន្ធ័ ហើយដែនកំណត់នៃការធ្វើសំណងនឹងត្រូវរាប់បញ្ចូលផងដែរនូវថ្លៃសេវាកម្មផ្នែកច្បាប់ទាំងអស់ដែលបានកើតឡើង ទោះបីជាត្រូវចំណាយដោយក្រុមហ៊ុន ឬដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុន និងរាល់ការចំណាយថ្លៃសេវាកម្មផ្នែកច្បាប់ទាំងអស់ដែលអាចទទួលបានមកវិញ ពីបុគ្គលដែលត្រូវបានធានារ៉ាប់រងតាមរយៈអ្នកប្តឹងទាមទារសំណងណាមួយ ។

**ករណីលែកលែង**

កិច្ចសន្យាធានារ៉ាប់រងនេះមិនទទួលខុសត្រូវក្នុងករណី :

១. ការរងរបួសចំពោះកម្មករ និយោជិត

ការរងរបួសលើរាងកាយចំពោះបុគ្គលណាមួយដែលស្ថិតនៅក្នុងកិច្ចសន្យាការងារ ឬការបង្គាត់អោយធ្វើការងារជាមួយបុគ្គលដែលត្រូវបានធានារ៉ាប់រង ប្រសិនបើការទទួលខុសត្រូវក្នុងករណីរបួសលើរាងកាយនោះកើតឡើងដោយ និងក្នុងហេតុផលនៃការបំពេញការងាររបស់កម្មករ និយោជិតទាំងនោះតាមរយៈបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬការរងរបួសលើរាងកាយកើតឡើងចំពោះសមាជិកគ្រួសារណាមួយ និងការចំណាយណាមួយដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងដែលតម្រូវដោយច្បាប់ និង/ឬនីតិកម្មដែលពាក់ពន្ធ័នឹងរបួសលើរាងកាយដែលបង្កឡើងដោយហានិភ័យការងារ ។

២. ទ្រព្យសម្បត្តិដែលស្ថិតក្រោមការគ្រប់គ្រង ឬអាណត្តិព្យាបាល

ការខូចខាតទ្រព្យសម្បត្តិចំពោះ :

ក) ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ ឬមានកិច្ចសន្យាជួល ឬជួលអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬ

ខ) ទ្រព្យសម្បត្តិដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ ឬស្របច្បាប់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

ប៉ុន្តែករណីលើកលែងនេះមិនត្រូវបានអនុវត្តចំពោះការទទួលខុសត្រូវលើទ្រព្យសម្បត្តិដែលខូចខាតចំពោះ :

i) បរិវេណអគារ (រួមទាំងទ្រព្យសម្បត្តិទាំងអស់របស់ម្ចាស់ដី )ដែលជួលអោយ ឬមានកិច្ចសន្យាជួលអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

ii) បរិវេណអគារ (ព្រមទាំងទ្រព្យសម្បត្តិផ្សេងទៀត) ដែលមិនមែនជាកម្មសិទ្ធិ, កិច្ចសន្យាជួល ឬជួលអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ប៉ុន្តែបរិវេណអគារនោះត្រូវបានប្រតិបត្តិការអាជីវកម្មបណ្តោះអាសន្ន ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ប៉ុន្តែមិនមានសំណងផ្តល់ជូនសម្រាប់ការខូចខាតផ្នែកណាមួយនៃទ្រព្យសម្បត្តិនោះ ក្នុងករណីដែលបុគ្គលដែលត្រូវបានការធានារ៉ាប់រង បានប្រតិបត្តិការអាជីវកម្មហើយដែលការខូចខាតនោះ កើតចេញពីប្រតិបត្តិការនោះ ។

iii) យានយន្ត (ដែលមិនមែនជាកម្មសិទ្ធិ ឬប្រើប្រាស់ដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង) ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ ឬស្របច្បាប់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលការខូចខាតចំពោះទ្រព្យសម្បត្តិទាំងនោះកើតឡើងក្នុងខណៈដែលយានយន្តទាំងនោះស្ថិតនៅក្នុងកន្លែងចតយានយន្តដែលជាកម្មសិទ្ធិ ឬប្រតិបត្តិការដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង។ ការទទួលខុសត្រូវស្ថិតនៅក្នុងករណីលែកលែង ២(iii) នេះ នឹងមិនត្រូវអនុវត្តឡើយ ប្រសិនបើផ្នែកណាមួយនៃអាជីវកម្មរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង គឺជាកន្លែងចតយានយន្តដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬជាប្រិតបត្តិករសម្រាប់ការផ្តល់ជារង្វាន់ ។

(iv) ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់និយោជិត ។

៣. ទំនិញរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង

បណ្តឹងទាមទារសំណងដែលកើតឡើងដោយផ្ទាល់ ឬប្រយោលពីភាពខ្វះចន្លោះ ឬអនិបុណភាពក្នុងការផ្គត់ផ្គង់ ឬលក់ទំនិញ (រាប់បញ្ចូលផងដែរនូវសម្ភារសម្រាប់ផ្ទុកទំនិញ ) បន្ទាប់ពីទំនិញត្រូវបានផ្ទេរពីការគ្រប់គ្រង និងអាណត្តិព្យាបាលភាពជាក់ស្តែងរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬរបស់បុគ្គលណាមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ជាជាងទំនិញត្រូវបានផ្គត់ផ្គង់ ឬលក់នៅឯ ឬពីអាហារដ្ឋានដែលផ្តល់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងសម្រាប់និយោជិតរបស់ខ្លួនប្រើប្រាស់ ។

៤. ការបាត់បង់នូវតម្លៃប្រើប្រាស់

ការបាត់បង់នូវតម្លៃប្រើប្រាស់របស់ទ្រព្យសម្បត្តិដែលអាចប៉ះបាន ដែលមិនមែនជាការខូចខាត ឬការបំផ្លាញផ្នែករូបវន្តដែលបណ្តាលមកពី :

ក) ភាពយឺតយ៉ាវ ឬការអនុវត្តមិនបានពេញលេញដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវកិច្ចសន្យា ឬកិច្ចព្រមព្រៀងណាមួយ

ខ) ភាពបរាជ័យលើទំនិញរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលមិនអាចឈានដល់កម្រិតនៃការអនុវត្ត, គុណភាព, ភាពសមរម្យ ឬការប្រើប្រាស់បានយូរ ឬតម្រូវតាមការធានា ឬតំណាងអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ប៉ុន្តែករណីលើកលែងនេះមិនអនុវត្តចំពោះ ការបាត់បង់នូវតម្លៃប្រើប្រាស់ របស់ទ្រព្យសម្បត្តិដែលអាចប៉ះបានដទៃទៀតដែលបណ្តាលមកពីគ្រោះថ្នាក់ភ្លាមៗ បណ្តាលអោយរបួសលើរាងកាយ ឬការបំផ្លាញទំនិញរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង បន្ទាប់ពីទំនិញទាំងនោះត្រូវបានដាក់អោយប្រើប្រាស់ដោយបុគ្គល ឬអង្គភាពណាមួយដែលមិនមែនជាបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

៥. ការកើនឡើងនូវសម្ពាធនៃគ្រឿងម៉ាស៊ីន (ប្រពន្ធ័ចំហាយទឹក)

បណ្តឹងទាមទារសំណងក្នុងករណីរបួសលើរាងកាយ ឬខូចខាតទ្រព្យសម្បត្តិដែលកើតឡើងផ្ទាល់ ឬប្រយោលពីការផ្ទុះ ឬការខូចខាតផ្នែកប្រពន្ធ័ចំហាយទឹក ឬឡចំហុយ, ម៉ាស៊ីនដើរដោយចំហាយទឹក ឬម៉ាស៊ីនដទៃទៀតដែលរងសម្ពាធ :

ក) ដែលជាកម្មសិទ្ធិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬ

ខ) ដែលស្ថិតក្រោមការគ្រប់គ្រងជាក់ស្តែង ឬស្របច្បាប់ ឬប្រើប្រាស់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ហើយក្នុងករណីដែលវិញ្ញាបនប័ត្រត្រូវបានតម្រូវអោយចេញដោយអនុលោមតាមខចែងនៃលក្ខន្តិកៈ ឬបទបញ្ជាផ្សេងៗ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយករណីលើកលែងនេះ មិនអនុវត្តចំពោះ សម្ពាធនៃគ្រឿងម៉ាស៊ីនដែលមានកំលាំងតិចជាង ឬស្មើនឹងមួយម៉ែត្រគូប ។

៦. យន្តហោះ និងកប៉ាល់ទឹក

បណ្តឹងទាមទារសំណងដែលកើតឡើងពីភាពជាកម្មសិទ្ធិ, ការថែទាំ, ប្រតិបត្តិការ ឬការប្រើប្រាស់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវ :

ក) យន្តហោះណាមួយ, យានដែលអាចហោះហើរលើអាកាស ឬ

ខ) កប៉ាល់ទឹកណាមួយ ឬនាវា

៧. យានយន្ត

ការខូចខាតទ្រព្យសម្បត្តិ ឬរបួសលើរាងកាយដែលកើតឡើងដោយសារភាពជាម្ចាស់កម្មសិទ្ធិ, ការកាន់កាប់, ការប្រតិបត្តិ, ការគ្រប់គ្រង, ការថែទាំ ឬការប្រើប្រាស់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវយានយន្តណាមួយ :

ក) ដែលមានការចុះបញ្ជី ឬ

ខ) ដែលតម្រូវដោយច្បាប់ណាមួយអោយចុះបញ្ជី

គ) ដែលក្នុងករណីមានការធានារ៉ាប់រងណាមួយត្រូវបានតម្រូវអោយមានសុពលភាពដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងដោយអនុលោមតាម ឬស្ថិតក្រោមច្បាប់ណាមួយ ថាតើការធានារ៉ាប់រងនោះមានសុពលភាព ឬអត់ ។

ករណីលើកលែងទី ៧ក ដល់ ៧គ មិនអនុវត្តចំពោះការខូចខាតទ្រព្យសម្បត្តិ ឬរបួសលើរាងកាយ :

i) ដែលបណ្តាលមកពី ឬកើតឡើងពីការបញ្ជូន ឬការប្រមូលទំនិញពី ឬដោយយានយន្តណាមួយ ដែលការខូចខាតទ្រព្យសម្បត្តិ ឬរបួសលើរាងកាយនោះ កើតឡើងដោយសារការហួសដែនកំណត់នៃការប្រើប្រាស់ផ្លូវ ឬដងវិថី

ii) កើតឡើងដោយសារការលើកឡើង ឬការដាក់ចុះនៃ ឬការបញ្ជូនទំនិញ ឬប្រមូលទំនិញពី ឬចំពោះយានយន្តណាមួយដែលប្រើប្រាស់ក្នុងការបំពេញការងារដែលស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង ប៉ុន្តែត្រូវស្ថិតក្រោមគ្រប់គ្រងដោយផ្ទាល់ ឬស្របច្បាប់របស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

៨. ការទទួលខុសត្រូវដែលបញ្ញត្តិដោយកិច្ចសន្យាការទទួលខុសត្រូវ ត្រូវបានកំណត់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយ លើកលែងតែមានការពង្រីក បន្ថែមនូវការទទួលខុសត្រូវនោះត្រូវបានតម្រូវដោយច្បាប់ ។

៩. ការសាងសង់អគារ

បណ្ដឹងទាមទារសំណងក្នុងករណីខូចខាតទ្រព្យសម្បត្តិ ឬរបួសលើរាងកាយដែលកើតឡើងដោយផ្ទាល់ ឬប្រយោល ឬបង្កឡើងដោយ ឬជាប់ទាក់ទងនឹងការសាងសង់, ការកំទេចចោល, ការកែប្រែនិ/ឬ ការសាងសង់អគារបន្ថែមដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង លើកលែងតែ ការសាងសង់, ការកំទេចចោល, ការកែប្រែ ឬការសង់បន្ថែមនោះមិនលើសពីចំនួនទឹកប្រាក់ ១០.០០០ដុល្លារ ។

១០. ការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈ

ការផ្ដល់ជូននូវ ឬការមិនបានផ្ដល់សេវាកម្ម ឬដំបូន្មានប្រកបដោយវិជ្ជាជីវៈដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬកំហុសឆ្គងណាមួយ ឬការភ្លេចភ្លាំងណាមួយ ប៉ុន្ដែករណីលើកលែងនេះមិនអនុវត្តចំពោះការផ្ដល់ជូន ឬការមិនបានផ្ដល់ដំបូន្មានផ្នែកជំនាញវិជ្ជសាស្ត្រដោយគ្រូពេទ្យដែលបំរើការងារអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងការផ្ដល់ជូននូវសេវាសង្គ្រោះបឋម និងសេវាកម្មផ្នែកវិជ្ជសាស្ត្រនៅក្នុងបរិវេណអគាររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង។

១១. រំញ័រ

បណ្ដឹងទាមទារសំណងក្នុងករណីខូចខាតចំពោះដី ឬទ្រព្យសម្បត្តិដែលមានជាប់នឹងដី ទោះបីជាកើតឡើងដោយផ្ទាល់ ឬប្រយោលពីរំញ័រ ។

១២. អត្ថបទបង្ខូចកេរ្តិ៍ឈ្មោះ និងការនិយាយបង្ខូចកេរ្តិ៍ឈ្មោះ

ការទទួលខុសត្រូវកើតឡើងពីការផ្សាយជាសាធារណៈ ឬការនិយាយពីមាត់មួយទៅមាត់មួយនៃអត្ថបទបង្ខូចកេរ្តិ៍ឈ្មោះ ឬការនិយាយបង្ខូច ឬបង្អាប់កេរ្តិ៍ឈ្មោះ ។

១៣. ការបំពុល

ក) ការខូចខាតលើទ្រព្យសម្បត្តិដែលបណ្ដាលមកពី ឬកើតឡើងពីការបញ្ចេញចោល, ការបែកខ្ញែក, ការរំដោះ ឬការបញ្ជៀសនៃសារធាតុកខ្វក់ចូលទៅក្នុង ឬលើដី, បរិយាកាស ឬប្រឡាយទឹក ឬបឹងណាមួយ ។ ករណីលើកលែងនេះមិនត្រូវបានអនុវត្តឡើយប្រសិនបើ ការបញ្ចេញចោល, ការបែកខ្ញែក, ការរំដោះ ឬការបញ្ជៀសកើតឡើងភ្លាមៗ, អាចកំណត់អត្តសញ្ញាណបាន, ដោយអចេតនា និងមិនអាចនឹកស្មានដល់ ហើយបានកើតឡើងក្នុងទីកន្លែង និងពេលវេលាមួយជាក់លាក់ ។

ខ) រាល់ថ្លៃ និងការចំណាយដែលបានកើតឡើងក្នុងការទប់ស្កាត់, ការរើចេញ, ការលុបបំបាត់ ឬការសម្អាតនៃការឆ្លងរោគ ឬភាពកខ្វក់ ប៉ុន្ដែទោះបីជាយ៉ាងណាក៏ដោយករណីលើកលែងទី ១៣ (ខ) នឹងមិនត្រូវអនុវត្តចំពោះការចំណាយលើការសម្អាត, ការរើចេញ ឬការលុបបំបាត់ដែលហេតុការណ៍ទាំងនោះបានកើតឡើងភ្លាមៗ, អាចកំណត់អត្តសញ្ញាណបាន, ដោយមិននឹកស្មានដល់ និងដោយអចេតនាកើតឡើងក្នុងទីកន្លែង និងពេលវេលាមួយជាក់លាក់ ដែលជាលទ្ធផលបណ្ដាលអោយរបួសលើរាងកាយ និង/ឬខូចខាតទ្រព្យសម្បត្តិ ។

១៤. កំហុសឆ្គងផ្នែកទឹកដៃ ឬជំនាញ

ថ្លៃចំណាយដែលបានកើតឡើងដើម្បីបំពេញ, កែលំអ ឬធ្វើអោយប្រសើរឡើងចំពោះការងារណាមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

១៥. ប្រាក់ពិន័យ និងទោសបញ្ញត្តិ

ប្រាក់ពិន័យ, ទោសបញ្ញត្តិ ឬការទូទាត់ការខូចខាត, ការដាក់ទណ្ឌកម្ម ឬការយកគំរូតាម និង/ឬការខូចខាតកាន់តែធ្ងន់ធ្ងរឡើង និង/ឬការខូចខាតបន្ថែមទៀតណាមួយ ដែលជាលទ្ធផលបណ្ដាលមកពីការកើនឡើងនូវការខូចខាតដោយឥតឈប់ឈរ ។

**ការធានារ៉ាប់រងបន្ថែម**

ការធានារ៉ាប់រងនៅក្នុងផ្នែកនេះពង្រីកវិសាលភាពនៃការទទួលខុសត្រូវដូចខាងក្រោមនេះ ដោយដែនកំណត់នៃការធ្វើសំណងមិនត្រូវលើសពីចំនួនដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធឡើយ :

១. អគ្គិភ័យ និងការផ្ទុះនានា

វាគឺជាការព្រមព្រៀងជាមុន និងប្រកាសថា កិច្ចសន្យាធានារ៉ាប់រងនេះបានពង្រីកបន្ថែមនូវការទទួលខុសត្រូវចំពោះហានិភ័យនៃ "អគ្គិភ័យ និងការផ្ទុះនានា" ។ ប៉ុន្ដែទោះបីក្នុងកាលៈទេសៈណាក៏ដោយ ដោយផ្អែកលើបង្គិលេខនេះក្រុមហ៊ុននឹងមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចណាមួយក្នុងករណីដែលការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិ ឬរបួសលើរាងកាយដែលបណ្ដាលមកពី ឬជាប់ទាក់ទងជាមួយ ឬកើតឡើងពីការបែកធ្លាយនៃប្រដាប់តម្លើងកំដៅរបស់ឡចំហុយ (boiler economizer) ឬម៉ាស៊ីនដែលដើរដោយសម្ពាធចំហាយទឹកផ្សេងៗ (vessel machine) ឬឧបករណ៍ដែលមានសម្ពាធខាងក្នុងដោយសារការស្ទុះកម្ដៅ ។

២. កីឡា និងសកម្មភាពសង្គម

វាជាការព្រមព្រៀងជាមុនដែលថា កិច្ចសន្យាធានារ៉ាប់រងនេះ និងពង្រីកវិសាលភាពនៃការទទួលខុសត្រូវចំពោះការស្លាប់ ឬរបួសរាងកាយដែលបណ្ដាលមកពី ឬកើតឡើងពីបញ្ហាយាយីអាយុជីវិតដែលមាននៅក្នុងម្ហូបអាហារ ឬភេសជ្ជៈដែលបានលក់ ឬផ្គត់ផ្គង់ដោយបុគ្គលដែលត្រូវបាន

ធានារ៉ាប់រងនៅឯ ឬពីបរិវេណអគារដូចដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធពោលគឺ "ដែនកំណត់នៃការទទួលខុសត្រូវ" ។ដោយហេតុនេះ ការទទួលខុសត្រូវរបស់ ក្រុមហ៊ុនក្នុងផ្នែកនេះ នឹងមិនត្រូវលើសពីដែនកំណត់ដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ ក្នុងករណីដែលកើតឡើងចំពោះបុគ្គលណាមួយ ឬបុគ្គលផ្សេងទៀតដែលជាលទ្ធផលកើតចេញពីហេតុការណ៍តែមួយ ។

## ផ្នែកទី ២ (ខ)_អំពើចោរកម្ម

**ការទទួលខុសត្រូវ**

ក្រុមហ៊ុននឹងធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង លើការបាត់បង់ដោយអំពើចោរកម្មដែលបណ្តាលមកពីការចេញ ឬចូលក្នុងបរិវេណអគារដោយប្រើកំលាំង និងហិង្សា ឬប្រព្រឹត្តដោយបុគ្គលម្នាក់ ឬបុគ្គលផ្សេងទៀត (ក្រៅពីនិយោជិត) ដែលលាក់បាំងពីច្បាប់ ។

**ករណីលើកលែង**

ក្រុមហ៊ុនមិនទទួលខុសត្រូវក្នុងករណី :

១. ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីអំពើចោរកម្មដូចមានចែងខាងលើ ឬការប៉ុនប៉ងណាមួយដោយគ្រួសាររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង, និយោជិត, អ្នកបម្រើក្នុងផ្ទះ ឬបុគ្គលណាម្នាក់ដែលរស់នៅស្របច្បាប់ក្នុងបរិវេណអគារ ។

២. ការបាត់បង់ ឬការខូចខាតចំពោះ មេដាយ, កាក់ប្រាក់, វត្ថុកម្រ, រូបចម្លាក់, ស្នាដៃសិល្បៈ, សៀវភៅកម្រ, ប្លង់, ប៉ាន់គំរូ, ពុម្ព, ការរចនា, ឯកសារប័ណ្ណកម្មសិទ្ធិផ្សេងៗ, ប័ណ្ណបំណុល, ប័ណ្ណសន្យាសងប្រាក់, ប្រាក់កាស, ធនបត្រ, ត្រា, ឯកសារសម្គាល់កម្មសិទ្ធ ឬសៀវភៅពាណិជ្ជកម្ម ។

៣. ការបាត់បង់ ឬការខូចខាតកើតឡើងដោយសារបរិវេណអគារត្រូវបានទុកទំនេរចោល ក្នុងរយៈពេលលើសពី ៣០ ថ្ងៃ ។

៤. ការបាត់បង់កើតឡើងក្នុងទីធ្លាស្មៅណាមួយ, សួនច្បារ, អគារនានាដែលស្ថិតក្នុងបរិវេណតែមួយ ឬទីកន្លែងសហកម្មសិទ្ធិដទៃទៀត ។

**ការធានារ៉ាប់រងបន្ថែម**

១. ការខូចខាតចំពោះបរិវេណអគារ :

ការធានារ៉ាប់រងក្នុងផ្នែកនេះបានពង្រីកវិសាលភាពនៃការទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតបរិវេណអគារដែលត្រូវបានធានារ៉ាប់រងរួមមាន: ក្លោងទ្វារ, របង និងរបស់សហកម្មសិទ្ធិផ្សេងៗទៀតដែលបណ្តាលមកពី ឬកើតឡើងពីលទ្ធផលនៃអំពើចោរកម្មរហូតដល់ចំនួនទឹកប្រាក់ ២៥០ ដុល្លារ ។

២. អំពើប្លន់/ការប្លន់ប្រដាប់អាវុធ

ការធានារ៉ាប់រងនៅក្នុងផ្នែកនេះបានពង្រីកបន្ថែមការទទួលខុសត្រូវលើហានិភ័យនៃអំពើប្លន់/ការប្លន់ប្រដាប់អាវុធដែលកើតឡើងក្នុងបរិវេណអគារ ។ ពាក្យថា "អំពើប្លន់/ការប្លន់ប្រដាប់អាវុធ" មានន័យថា ជាការបាត់បង់នូវទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង :

i) តាមរយៈការបង្ករបួសដោយអំពើហិង្សាទៅលើអ្នកមើលថែរក្សា ។

ii) តាមរយៈការធ្វើអោយភ័យខ្លាចដោយអំពើហិង្សា ។

iii) ពីអ្នកថែរក្សាដែលត្រូវបានសម្លាប់ ឬធ្វើអោយបាត់បង់ស្មារតី ។

**លក្ខខណ្ឌ**

១. អំពើឆបោក

ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពី ឬចូលរួមចំណែកពីសកម្មភាពនៃអំពើឆបោកដោយបុគ្គលណាមួយដោយផ្អែកតាមនិយមន័យនៃអំពើឆបោកដូចខាងក្រោម :

"ជនណាដែលតាមរយៈការបោកបន្លំជនណាម្នាក់ទៀត បញ្ឆេះបញ្ឆូលដោយបន្លំ ឬដោយមិនស្មោះត្រង់ជនណាម្នាក់ទៀតអោយចាញ់បោកព្រមប្រគល់ទ្រព្យសម្បត្តិណាមួយ ឬបញ្ឆេះបញ្ឆូលដោយចេតនាជនណាម្នាក់ទៀត អោយចាញ់បោកព្រមធ្វើអំពើ ឬមិនធ្វើអំពើណាមួយ ដែលជននោះនឹងមិនធ្វើ ឬមិនខកខានធ្វើឡើយ ប្រសិនបើខ្លួនពុំត្រូវបានគេបោកបន្លំទេនោះ ហើយដែលអំពើ ឬការមិនធ្វើអំពើនោះបង្កអោយមាន ឬអាចបង្កអោយមានការខូចខាត ឬបង្កគ្រោះថ្នាក់ដល់បុគ្គលនោះទាំងផ្លូវកាយ, ផ្លូវចិត្ត, កេរ្តិ៍ឈ្មោះ ឬទ្រព្យសម្បត្តិ អោយឈ្មោះថា "អំពើឆបោក" " ។

២. បទល្មើសរំលោភលើសេចក្តីទុកចិត្ត

ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពី ឬចូលរួមចំណែកពីសកម្មភាពនៃបទល្មើសរំលោភលើសេចក្តីទុកចិត្តដោយបុគ្គលណាមួយ ដោយស្ថិតក្នុងអត្ថន័យនៃនិយមន័យបទល្មើសរំលោភលើសេចក្តីទុកចិត្តដូចខាងក្រោម :

"ជនណាដែលត្រូវបានគេផ្ញើទុកនូវទ្រព្យសម្បត្តិណាមួយ ទោះតាមវិធីណាក៏ដោយ ឬដែលមានសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិមួយ បន្លំយកដោយទុច្ចរិតនូវទ្រព្យសម្បត្តិនោះ ឬបង្វែរទ្រព្យសម្បត្តិនោះមកជាការប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ ឬចាត់ចែងទ្រព្យសម្បត្តិនោះដោយទុច្ចរិតដោយ

រំលោភលើវិធានច្បាប់ដែលបញ្ញត្តិពីរបៀបដោះបន្ទុកពីការផ្ញើទុកនោះ ឬរំលោភលើកិច្ចសន្យាតាមផ្លូវច្បាប់ដោយជាក់លាក់ ឬដោយតុល្យភាព ដែលអនុញ្ញាតអោយ ខ្លួនដោះបន្ទុកពីការផ្ញើទុកនោះ ឬដោយចេតនាបង្កអោយបុគ្គលដទៃទទួលរងនូវការខូចខាតដោយអំពើខាងលើត្រូវបានចាត់ទុកថា "បទល្មើសរំលោភលើសេចក្តីទុកចិត្ត" ។

## ផ្នែកទី ២ (គ) រូបិយវត្ថុ

**និយមន័យ**

ពេលវេលាបំពេញការងារ មានន័យថាជាពេលវេលាបំពេញការងារការិយាល័យរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង និងម៉ោងធ្វើការ (រួមទាំងការងារថែមម៉ោង) ក្នុងអំឡុងពេលដែលបុគ្គលដែលត្រូវធានារ៉ាប់រង ឬមន្រ្តីផ្នែកប្រតិបត្តិ និងអគ្គនាយករបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬនិយោជិត បានរៀបចំទុកដាក់នូវប្រាក់កាសរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងនៅក្នុងបរិវេណអគារសម្រាប់ក្នុងគោលបំណងពាណិជ្ជកម្ម ។

អ្នកដែលមានតួនាទីសំខាន់ មានន័យថា ជាមន្រ្តីប្រតិបត្តិ និងអគ្គនាយករបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ប៉ុន្តែក្នុងករណីដែលពួកគេបំពេញតួនាទីជាអគ្គនាយកប៉ុណ្ណោះ ។

រូបិយវត្ថុ មានន័យថា ជាសាច់ប្រាក់, ធនប័ត្រ និងក្រដាសប្រាក់, មូលប្បទានបត្រ, ប័ណ្ណផ្ញើរប្រាក់តាមរយៈប្រៃសណីយ៍, រូបិយាណត្តិ, វិក័យប័ត្រលក់, ប័ណ្ណតម្លៃ និងចំណូលប្រៃណីយ៍, ប័ណ្ណសន្យាបើកប្រាក់, សំបុត្រប្រៃណីយ៍ និងប័ណ្ណចំណូលប្រៃណីយ៍ ព្រមទាំងប័ណ្ណធានាផ្សេងៗទៀតដែលអាចប្តូរជាប្រាក់បាន, ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬទ្រព្យសម្បត្តិដែលស្ថិតក្រោមអាណត្តិព្យាបាលភាព ឬការគ្រប់គ្រងរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

**ការទទួលខុសត្រូវ**

ក្រុមហ៊ុននឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រង ចំពោះការបាត់បង់ប្រាក់កាសក្នុងខណៈពេលដែល :

១. ដឹកជញ្ជូនគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជាដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬដោយនិយោជិតដែលមានការអនុញ្ញាត ។
២. ស្ថិតនៅក្នុងបរិវេណអគាររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយក្នុងនោះប្រាក់កាសទាំងនោះត្រូវបានរក្សាទុកនៅក្នុងទូសុវត្ថិភាពបិទជិត, ក្នុងម៉ាស៊ីនគិតលុយ, ក្នុងថតតុ ឬបន្ទប់ដែលមិនឆេះគ្រប់ពេលទាំងអស់បន្ទាប់ពីពេលបញ្ចប់ម៉ោងបំពេញការងារ ។

**ករណីលើកលែង**

ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការបាត់បង់ប្រាក់កាស

១. ដែលជាលទ្ធផលនៃការខ្វះចន្លោះដោយសារកំហុសឆ្គងផ្នែកគណនេយ្យ ឬការភ្លេចភ្លាំង ឬការកាត់រំលស់ ឬដោយសារការប្រើប្រាស់រូបិយប័ណ្ណក្លែងក្លាយ ។
២. ដោយសារការប្រគល់ទូសុវត្ថិភាពអោយបុគ្គលណាមួយ ដែលមិនមែនជាបុគ្គលដែលត្រូវបានធានារ៉ាប់រង, អគ្គនាយក ឬនិយោជិតរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។
៣. តាមរយៈការឃុបឃិត ឬលួចបន្លំដោយ ឬលួចបន្លំយកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬសមាជិកគ្រួសារណាមួយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬបុគ្គលណាមួយ ឬបុគ្គលដទៃទៀត ដែលបម្រើការងារអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ។
៤. ពីយានយន្តដែលមិនមានការយាមកាម ។
៥. ពីទូសុវត្ថិភាព, បន្ទប់ដែលមិនឆេះ ឬកន្លែងផ្សេងទៀតតាមរយៈការប្រើប្រាស់កូនសោ ឬលេខសោទូដែកសម្ងាត់ ឬបន្ទប់ដែលមិនឆេះ ឬកន្លែង ផ្សេងទៀត លែកលែងតែកូនសោ ឬលេខសោសម្ងាត់ត្រូវបានកាន់កាប់ដោយអ្នកដទៃ តាមរយៈការគំរាមកំហែង ឬដោយប្រើហិង្សា ។

**ការធានាបន្ថែម**

១. ការបាត់បង់/ការខូចខាតចំពោះទូសុវត្ថិភាព/បន្ទប់ការពារអគ្គិភ័យ (បន្ទប់ដែលមិនឆេះ)
ការធានារ៉ាប់រងនៅក្នុងផ្នែកនេះបានពង្រីកវិសាលភាពនៃការទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតចំពោះទូសុវត្ថិភាព ឬបន្ទប់ការពារអគ្គិភ័យរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលជាលទ្ធផលផ្ទាល់កើតពីការប៉ុនប៉ងណាមួយដើម្បីរើកកាយសម្ភារដែលចាក់សោក្នុងទូសុវត្ថិភាពឬបន្ទប់ការពារអគ្គិភ័យរហូតដល់ចំនួនទឹកប្រាក់ ២០០ ដុល្លារ ។

## ផ្នែកទី ២ (ឃ) គ្រោះថ្នាក់បុគ្គល

**ការធ្វើសំណង**

ក្រុមហ៊ុននឹងធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬបុគ្គលតំណាងស្របច្បាប់ដូចដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យានេះ ប្រសិនបើក្នុងអំឡុងពេលនៃការធានារ៉ាប់រង បុគ្គលដែលត្រូវបានធានារ៉ាប់រងមានអាយុចាប់ពី ១៦ឆ្នាំ ដល់ ៦៥ឆ្នាំ ទទួលរងរបួសលើរាងកាយបង្កឡើងទាំងស្រុង នឹងដោយផ្ទាល់ដោយសារ

កត្តាគ្រោះថ្នាក់ពីខាងក្រៅ និងដែលមើលឃើញនឹងភ្នែក និងជាមូលហេតុតែមួយគត់ និងដោយផ្ទាល់នៃការស្លាប់ ឬពិការភាពជាអចិន្ត្រៃយ៍ដែលកើតឡើងគ្រប់ទីកន្លែងលើពិភពលោកក្នុងរយៈពេល ១២ខែ បន្តបន្ទាប់គ្នាក្រោយកាលបរិច្ឆេទនៃការរងរបួសលើរាងកាយ ។

**និយមន័យ**

១. "ពិការភាពជាអចិន្ត្រៃយ៍ " មានន័យថាជាការបាត់បង់នូវការប្រើប្រាស់ទាំងស្រុង និងដែលមិនអាចជាសះស្បើយបាននៃផ្នែកអវយវៈណាមួយ ឬផ្នែកដទៃទៀតដែលមានបញ្ជាក់នៅក្នុងតារាងមូលដ្ឋាននៃការធ្វើសំណង ។

២. "ការបាត់បង់នូវចក្ខុប្រសាទ "មានន័យថាជាការបាត់បង់នូវរបកគំហើញទាំងស្រុង និងដែលមិនអាចជាសះស្បើយបាន ។

**ករណីលើកលែង**

អនុវត្តតែចំពោះផ្នែកទី១ (ខ) គ្រោះថ្នាក់ចំពោះនិយោជិត និងផ្នែកទី២ (គ) គ្រោះថ្នាក់បុគ្គល

ក្រុមហ៊ុននឹងមិនធ្វើសំណងចំពោះបណ្តឹងទាមទារសំណងដែលកើតឡើងដោយផ្ទាល់ពី :

១. ការធ្វើអត្តឃាត, ការបំផ្លាញខ្លួនឯង, ការបង្ករបួសដោយខ្លួនឯង ឬការប៉ុនប៉ងណាមួយទោះបីជាមានសតិប្រក្រតី ឬមិនប្រក្រតីក្តី ។

២. ជំងឺបណ្តុំរោគសញ្ញាប្រព័ន្ធភាពស៊ាំចុះខ្សោយ (អេដស៍) ឬជំងឺឆ្លងតាមរយៈការរួមភេទ ។

៣. លទ្ធផលនៃឥទ្ធិពលគ្រឿងស្រវឹង ឬថ្នាំញៀនដែលមិនមែនជាថ្នាំសម្រាប់ព្យាបាលតាមវិជ្ជបញ្ជា ឬតាមការណែនាំរបស់គ្រូពេទ្យ ។

៤. យានហោះ ឬសកម្មភាពក្នុងអាកាសជាជាងការធ្វើដំណើរក្នុងយន្តហោះក្នុងឋានៈជាអ្នកដំណើរ ប៉ុន្តែមិនមែនក្នុងឋានៈជាសមាជិកនៃក្រុមអាកាសយានិក ឬសម្រាប់គោលបំណងធ្វើជំនួញ ឬប្រតិបត្តិការបច្ចេកទេសនៅក្នុងយន្តហោះនោះទេ ។

៥. សកម្មភាពខុសច្បាប់របស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

៦. ការបម្រើការងារក្នុងកងកំលាំងទាហានជើងទឹក, យោធា ឬកងទ័ពអាកាស ឬប្រតិបត្តិការផ្សេងៗទៀត ជាជាងរបួសដែលកើតឡើងដោយសារបុគ្គលដែលត្រូវបានធានារ៉ាប់រងជាស្ត្រីមានគភ៌ ឬការប្រសូតកូន ។

៧. បុគ្គលដែលត្រូវបានធានារ៉ាប់រងមានការជាប់ពាក់ព័ន្ធក្នុង ឬផ្នែកណាមួយនៃការបើកបរ ឬជាអ្នកដំណើរក្នុងសកម្មភាពកីឡាប្រកួតប្រជែងគ្រប់ប្រភេទ ឬកីឡាអាជីព ។

៨. ជំងឺដែលមានមុនការធានារ៉ាប់រង ឬជំងឺផ្សេងៗទៀត ។

**ការធានារ៉ាប់រងបន្ថែម**

អនុវត្តតែចំពោះផ្នែកទី១ (ខ) គ្រោះថ្នាក់ចំពោះនិយោជិត និងផ្នែកទី២ (គ) គ្រោះថ្នាក់បុគ្គល

ការធានារ៉ាប់រងនៅក្នុងផ្នែកនេះពង្រីកវិសាលភាពនៃការទទួលខុសត្រូវលើ :

១. ការរើឡើងវិញនៃរបួស

នៅពេលដែលមានការរើឡើងវិញនៃរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង ហើយជាលទ្ធផលការរើឡើងវិញនៃរបួសនោះបណ្តាលអោយបាត់បង់ជីវិត នោះការបាត់ជីវិតនោះនឹងត្រូវបានធ្វើសំណងដោយផ្អែកតាមលក្ខខណ្ឌនេះ ។

២. ការបាត់ខ្លួន

ប្រសិនបើសាកសពរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងមិនត្រូវបានរកឃើញ ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីថ្ងៃដែលបានបាត់ខ្លួនដោយការលិច ឬការបុកប៉ះទង្គិចនៃមធ្យោបាយដឹកជញ្ជូន ដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងកំពុងធ្វើដំណើរខណៈពេលដែលទទួលរងរបួស ហើយក្នុងស្ថានភាពបែបនោះនឹងត្រូវបានធ្វើសំណង ដោយផ្អែកលើលក្ខខណ្ឌនៃការបាត់ខ្លួនរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ព្រមទាំងត្រូវបានចាត់ទុកថាជាបណ្តឹងទាមទារសំណងដែលមានលក្ខណៈស្របច្បាប់ស្ថិតក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ដោយហេតុថាប្រសិនបើពេលវេលាណាមួយ បន្ទាប់ពីក្រុមហ៊ុនបានបង់នូវសំណងសម្រាប់បណ្តឹងទាមទារសំណងនោះ ហើយបុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវបានរកឃើញថានៅរស់រានមានជីវិត នោះក្រុមហ៊ុននឹងត្រូវបានទទួលមកវិញនូវចំនួនទឹកប្រាក់ដែលខ្លួនបានបង់ ។

៣. សត្វល្អិត, សត្វចិញ្ចឹម ឬពស់ខាំ ឬទិច

ក្រុមហ៊ុននឹងធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង ចំពោះការស្លាប់ ឬរបួសលើរាងកាយ ឬការចំណាយលើថ្នាំព្យាបាលរបួស (ប្រសិនបើត្រូវបានធានា) ដែលកើតឡើងដោយផ្ទាល់ពី ឬជាលទ្ធផលមកពីសត្វល្អិត, សត្វចិញ្ចឹម ឬពស់ខាំ ឬទិច ។ ទោះបីជាយ៉ាងណាក៏ដោយ ការធានារ៉ាប់រងបន្ថែមនេះនឹងមិនទទួលខុសត្រូវលើការស្លាប់, របួសលើរាងកាយ ឬការចំណាយលើថ្នាំព្យាបាលរបួស ប្រសិនបើការស្លាប់ ឬរបួសលើរាងកាយ ឬការព្យាបាល គឺជាលទ្ធផលបណ្តាលមកពីជំងឺ ឬរោគផ្សេងៗដែលកើតចេញមកពីសត្វល្អិត, សត្វចិញ្ចឹម ឬពស់ខាំ ឬទិច ។

៤. ខចែងស្តីអំពីគ្រោះថ្នាក់បណ្តាលមកពីការហឺត ឬស្រូបឧស្ម័ន, ការលង់ទឹក និងការពុលអាហារ

ក្រុមហ៊ុននឹងធ្វើសំណងចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង ចំពោះការស្លាប់ ឬពិការភាពជាអចិន្ត្រៃយ៍ ដែលកើតឡើងដោយសារ ឬជាលទ្ធផលបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុនៃការហឹត ឬស្រូបឧស្ម័ន, ការលង់ទឹក, ការពុលអាហារ ឬគ្រោះថ្នាក់ស្រដៀងគ្នានេះដោយមាន ឬមិនមានសញ្ញាណពីខាងក្រៅ ឬកត្តាគ្រោះថ្នាក់ពីខាងក្រៅ នឹងដែលមើលឃើញនឹងភ្នែក ។

**លក្ខខណ្ឌ**

អនុវត្តតែចំពោះផ្នែកទី១ (ខ) គ្រោះថ្នាក់ចំពោះនិយោជិត និងផ្នែកទី២ (គ) គ្រោះថ្នាក់បុគ្គល

១. បន្ទាប់ពីមានរបួសលើរាងកាយ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវតែយក និងអនុវត្តតាមវិជ្ជបញ្ជារបស់គ្រូពេទ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបានផ្តល់នូវលិខិតបញ្ជាក់អំពីសភាព និងទំហំនៃរបួស ។

២. ការធានារ៉ាប់រងនៅក្នុងផ្នែកនេះអាចត្រូវបានចាត់ទុកជាមោឃៈ ក្នុងករណីដែលមានការបង្ហាញនូវព័ត៌មានមិនពិត, ការពិពណ៌នាមិនពិត, ឬការបង្ហាញមិនពិត ឬមានការបិទបាំងនូវស្ថានភាពណាមួយ ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងចំពោះ ឬពាក់ពន្ធ័ជាមួយនឹង :

- ក) សុខភាពរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងជាពិសេស
  - i. ថាតើបុគ្គលដែលត្រូវបានធានារ៉ាប់រងមានការឈឺចាប់ពីរោគផ្សេងៗ, ជំងឺ, អសមត្ថភាព ឬពិការភាព ឬ
  - ii. ថាតើបុគ្គលដែលត្រូវបានធានារ៉ាប់រង មានការទទួលស្គាល់តាមរយៈការណែនាំថា ខ្លួនអាចទទួលរងនូវជំងឺដោយសាររោគផ្សេងៗ, ជំងឺ, អសមត្ថភាព ឬពិការភាព
- ខ) បទពិសោធន៍ពីហានិភ័យពីមុន ដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងធ្លាប់ជួបប្រទះ និងប្រវត្តិនៃបណ្តឹងទាមទារសំណង ។
- គ) របាយការណ៍ស្តីពីការធានារ៉ាប់រងរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ព្រមទាំងរបាយការណ៍បដិសេធការធានារ៉ាប់រងពីមុន ។

បុគ្គលដែលត្រូវបានធានារ៉ាប់រងអាចត្រូវបានតម្រូវអោយផ្តល់ក្រុមហ៊ុន នូវរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីព័ត៌មានទាំងអស់ ឬនៅពេលវេលាណាមួយដែលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុន ។ គ្មានរបាយការណ៍ណាមួយដែលធ្វើឡើងដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងដោយផ្អែកលើកិច្ចសន្យានេះត្រូវបានទទួលស្គាល់ និងជាការដាក់កំហិតមកលើក្រុមហ៊ុនឡើយ លើកលែងតែខចែងនៃលក្ខខណ្ឌនេះត្រូវបានអនុវត្តទាំងស្រុង ។

| មូលដ្ឋានគ្រឹះនៃការដោះស្រាយសំណង<br>ហេតុការណ៍/គ្រោះថ្នាក់ | អត្ថប្រយោជន៍<br>(ភាគរយនៃចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង) % |
|---|---|
| ក. ស្លាប់ | ១០០ |
| ខ. ពិការភាពជាអចិន្ត្រៃយ៍នៃ : | |
| ១. បាត់បង់អវយវៈទាំងពីរ | ១០០ |
| ២. ពិការដៃទាំងពីរ | ១០០ |
| ៣. ភ្នែកទាំងពីរងងឹតទាំងស្រុង | ១០០ |
| ៤. ងងឹតភ្នែកម្ខាង និងបាត់បង់ដៃ ឬជើងម្ខាង | ១០០ |
| ៥. របួសដែលបណ្តាលអោយដេកលើគ្រែជាអចិន្ត្រៃយ៍ | ១០០ |
| ៦. បាត់បង់ដៃម្ខាងចាប់ពីកួយដៃឡើង | ១០០ |
| ៧. បាត់បង់ជើងម្ខាងចាប់ពីលើជង្គង់ឡើង | ១០០ |
| ៨. បាត់បង់ទាំងស្រុង និងដែលមិនអាចព្យាបាលបាននូវចក្ខុប្រសាទទាំងអស់នៃភ្នែកម្ខាង | ១០០ |
| ៩. បាត់បង់ម្រាមដៃបួន និងមេដៃម្ខាង | ៧០ |
| ១០. បាត់បង់មេដៃម្ខាង | ២៥ |
| ១១. បាត់បង់ម្រាមដៃចង្អុរ | ១០ |
| ១២. បាត់បង់ម្រាមដៃកណ្តាលមួយ | ៦ |
| ១៣. បាត់បង់ម្រាមដៃនាងមួយ | ៦ |
| ១៤. បាត់បង់កូនដៃមួយ | ៤ |
| ១៥. បាត់បង់មេជើងមួយ | ៥ |
| ១៦. បាត់បង់ម្រាមជើងផ្សេងទៀតក្រៅពីមេជើង | ៣ |

ចំនួនភាគរយនៃការធ្វើសំណងទាំងអស់ក្នុងគ្រោះថ្នាក់នីមួយៗ នឹងមិនត្រូវលើសពី ១០០% នៃចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងឡើយ ។

## ករណីលើកលែងទូទៅ_អនុវត្តចំពោះគ្រប់ផ្នែកទាំងអស់

១. ការខូចខាតដែលបណ្តាលមកពីនុយក្លេអ៊ែរ ឬការរឹបអូសដោយសារសង្គ្រាម

កិច្ចសន្យាធានារ៉ាប់រងនេះមិនធ្វើសំណងលើការបាត់បង់, ការខូចខាត, ការទទួលខុសត្រូវ ឬរបួសដែលបណ្តាលមកពី ឬជាប់ទាក់ទងនឹង :

ក) សង្គ្រាម, ការឈ្លានពាន, ទង្វើរបស់សត្រូវបរទេស, អរិភាព ឬប្រតិបត្តិការសង្គ្រាម (ទោះបីសង្គ្រាមនោះត្រូវបានប្រកាស ឬមិនប្រកាសក៏ដោយ), សង្គ្រាមស៊ីវិល, ការប៉ះបោរ, កុប្បកម្ម, ការក្រោកឈរប្រឆាំងដោយយោធា ឬប្រជាជន, ឧទ្ទាមកម្ម, ការធ្វើបដិវត្តន៍, ការចលាចល ឬការប្រើប្រាស់អំណាចយោធា ឬការដណ្តើមអំណាច ។

ខ) បទបញ្ជារបស់រដ្ឋាភិបាលណាមួយ, ការរឹបអូសទ្រព្យសម្បត្តិដោយអជ្ញាធរសាធារណៈ, ជាតូនីយកម្ម, ការប្តឹងផ្តល់នៃ ឬការធ្វើអោយខូចខាតនូវទ្រព្យសម្បត្តិណាមួយ ។

គ) ការចូលរួមចំណែកបង្កឡើង ឬកើតឡើងដោយសារវិទ្យុសកម្មអ៊ីយ៉ុង ឬការបំពុលដោយសារសកម្មភាពវិទ្យុសកម្មដែលភាយចេញពីសំណល់នុយក្លេអ៊ែរ ឬពីចំហេះឥន្ធនៈនុយក្លេអ៊ែរ ។ " ឥន្ធនៈនុយក្លេអ៊ែរ " មានន័យថា ជាវត្ថុទាំងឡាយណាដែលអាចផលិតចេញជាថាមពលតាមរយៈដំណើរការសង្វាក់ផលិតកម្មនៃការបំបែកសារធាតុនុយក្លេអ៊ែរដោយខ្លួនឯង ។

ឃ) សារធាតុវិទ្យុសកម្ម, សារធាតុពុល, សារធាតុផ្ទុះ ឬសារធាតុប្រកបដោយគ្រោះថ្នាក់ដទៃទៀត ឬការចម្លងរោគលើទ្រព្យសម្បត្តិដោយសារសកម្មភាពណាមួយនៃការតម្លើងនុយក្លេអ៊ែរ,ឧបករណ៍ត្រួតពិនិត្យកម្តៅ ឬការតម្លើងនុយក្លេអ៊ែរផ្សេងទៀត ឬសារធាតុផ្សំនុយក្លេអ៊ែរដទៃទៀត ។

ង) សព្វាវុធសង្គ្រាមគ្រប់ប្រភេទទោះបីប្រើដោយស្វ័យប្រវត្តិ ឬប្រើដោយដោយការបំបែកសារធាតុនុយក្លេអ៊ែរ និង/ឬការរំលាយបញ្ចូលគ្នា ឬដោយប្រតិកម្មដទៃទៀត ឬដោយកំលាំងវិទ្យុសកម្ម ឬរូបធាតុវិទ្យុសកម្ម ។

ច) សារធាតុវិទ្យុសកម្ម, សារធាតុពុល, សារធាតុផ្ទុះ ឬសារធាតុប្រកបដោយគ្រោះថ្នាក់ដទៃទៀត ឬការឆ្លងមេរោគលើទ្រព្យសម្បត្តិ ឬបញ្ហាទាំងឡាយដែលបង្កឡើងដោយសារធាតុវិទ្យុសកម្ម ។

ឆ) សារធាតុគីមីគ្រប់ប្រភេទ, អាវុធជីវសាស្ត្រ, អាវុធជីវគីមី ឬអាវុធប្រើដោយប្រពន្ធ័អេឡិចត្រូម៉ាញេទិច ។

២. ការផ្លាស់ប្តូរ ឬការកែប្រែ

កិច្ចសន្យាធានារ៉ាប់រងនេះមិនធ្វើសំណងចំពោះការបាត់បង់, ការខូចខាត, របួសលើរាងកាយ ឬការទទួលខុសត្រូវណាមួយដែលកើតឡើងពីការផ្លាស់ប្តូរណាមួយក្នុងប្រតិបត្តិការ ឬដំណើរការពាណិជ្ជកម្ម ដែលបានកើតឡើងក្នុងបរិវេណអគារ ឬមានការផ្លាស់ប្តូរប្រភេទនៃអាជីវកម្ម ឬ ស្ថានភាពផ្សេងទៀតដែលមានឥទ្ធិពលលើទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ដែលជាហេតុបណ្តាលអោយមានការកើនឡើងនូវហានិភ័យនៃការបាត់បង់ ឬការខូចខាត លើកលែងតែមានការជូនដំណឹងមកក្រុមហ៊ុនជាមុនអំពីការផ្លាស់ប្តូរទាំងនោះ ហើយបុគ្គលដែលត្រូវបានធានារ៉ាប់រង បានព្រមព្រៀងបង់បុព្វលាភធានារ៉ាប់រងបន្ថែមដូចដែលបានតម្រូវដោយក្រុមហ៊ុន ។

៣. អំពើភេរវកម្ម

ថ្វីបើមានបទប្បញ្ញត្តិណាមួយដែលផ្ទុយនឹងកិច្ចសន្យាធានារ៉ាប់រងនេះ ឬបដ្ឋិលេខណាមួយ នោះការធានារ៉ាប់រងនេះមិនរាប់បញ្ចូលនូវការខាតបង់ ការខូចខាត តម្លៃ ឬការចំណាយទៅលើអ្វីមួយដោយផ្ទាល់ ឬដោយប្រយោល កើតឡើងពី ឬជាប់ទាក់ទងនឹងអំពើភេរវកម្ម ដោយមិនគិតថាហេតុនៃអំពើដែលនាំឱ្យមានការខាតបង់នោះកើតនៅពេលតែមួយ ឬកើតឡើងជាបន្តបន្ទាប់គ្នាទេ ។

ចំពោះគោលបំណងនៃកិច្ចសន្យានេះ អំពើភេរវកម្មមាន ន័យថាជាអំពើជាអាទិ៍ ការប្រើប្រាស់កំលាំង ឬអំពើហិង្សា និង/ឬការគំរាមកំហែងរបស់បុគ្គល ឬក្រុមណាមួយ ទោះបីជាប្រព្រឹត្តតែម្នាក់ឯង ឬក្នុងនាមគេ ឬជាប់ពាក់ព័ន្ធនឹងអង្គការ ឬរដ្ឋាភិបាលណាមួយក្តី។ អំពើនោះប្រព្រឹត្តក្នុងគោលដៅនយោបាយ សាសនា មនោគមវិជ្ជាដែលមានចេតនាធ្វើឱ្យមានឥទ្ធិពលលើ រដ្ឋាភិបាល និង/ឬធ្វើឱ្យសាធារណជន ឬផ្នែកណាមួយនៃសាធារណជនមានការភ័យខ្លាច។

បដ្ឋិលេខនេះ ក៏លើកលែងនូវការខាតបង់ ការខូចខាត តម្លៃ ឬការចំណាយទៅលើអ្វីមួយដោយផ្ទាល់ ឬដោយប្រយោល កើតឡើងពី ឬជាប់ទាក់ទងនឹងសកម្មភាពណាមួយដែលធ្វើឡើងដើម្បីគ្រប់គ្រង ទប់ស្កាត់ គាបសង្កត់ ឬមធ្យោបាយណាមួយដែលទាក់ទងនឹងអំពើភេរវកម្ម។

ប្រសិនបើក្រុមហ៊ុនមានហេតុផលថា ការខាតបង់ ការខូចខាត តម្លៃ ឬការចំណាយដូចបានលើកលែងខាងលើ មិនត្រូវបានចេញសងដោយកិច្ចសន្យាធានារ៉ាប់រងនេះទេ អ្នកដែលត្រូវបានធានារ៉ាប់រងមានបន្ទុកក្នុងការបង្ហាញភស្តុតាងផ្ទុយ។

ក្នុងករណីដែលផ្នែកណាមួយនៃបដ្ឋិលេខនេះអសុពលភាព ឬមិនអាចអនុវត្តបាន ផ្នែកដែលនៅសល់នៅតែមានសុពលភាព និងប្រសិទ្ធិភាពពេញលេញ។

៤. ការបញ្ជាក់អំពីប្រពន្ធ័ព័ត៌មានវិទ្យា

យោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ ការធ្វើសំណងលើការខូចខាត មានតែទៅលើទ្រព្យសម្បត្តិដែលខូចខាតជារូបវ័ន្ត។

ការខូចខាតលើទ្រព្យសម្បត្តិជារូបវ័ន្ត មិនត្រូវរាប់បញ្ចូលការខូចខាតលើទិន្នន័យ ឬសូហ្វវែរ៍ ជាពិសេសការប្រែប្រួលបណ្តាលឱ្យខូចខាតដល់ទិន្នន័យ សូហ្វវែរ៍ ឬកម្មវិធីកុំព្យូទ័រ ដោយសារតែការលុបចោល ការបង្ខូច ឬការកែប្រែទំរង់ដើម។

កិច្ចសន្យាធានារ៉ាប់រងនេះ មិនរាប់បញ្ចូលនូវការខាតបង់ដូចខាងក្រោមនេះ :

ក. ការខូចខាតលើទ្រព្យសម្បត្តិជារូបវ័ន្ត មិនត្រូវរាប់បញ្ចូលចំពោះការខូចខាតលើទិន្នន័យ ឬសូហ្វវែរ៍ ជាពិសេសការប្រែប្រួលបណ្តាលឱ្យខូចខាតដល់ទិន្នន័យ សូហ្វវែរ៍ ឬកម្មវិធីកុំព្យូទ័រដោយសារតែការលុបចោល ការកែប្រែ ឬការធ្វើឱ្យខូចដល់ទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម និងការខាតបង់ផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីការរាក់ខានផ្នែកអាជីវកម្ម ដែលជាលទ្ធផលបណ្តាលមកពីការខាតបង់ ឬការខូចខាតទាំងនេះ។

ខ. ការខាតបង់ ឬការខូចខាតដែលបណ្តាលមកពីការធ្វើអោយខ្សោយដល់ការបំពេញមុខងារ មិនអាចប្រើប្រាស់ ឬទទួលបានទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ និងការខាតបង់ផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីការរាក់ខានផ្នែកអាជីវកម្ម ដែលជាលទ្ធផលបណ្តាលមកពីការខាតបង់ ឬការខូចខាតទាំងនេះ។

៥. រូបធាតុដែលដុតមិនឆេះ និងធន់នឹងប្រតិកម្មគីមី

កិច្ចសន្យាធានារ៉ាប់រងនេះមិនអនុវត្ត ឬមិនធ្វើសំណងចំពោះការទទួលខុសត្រូវជាក់ស្តែងសម្រាប់បណ្តឹងទាមទារសំណងណាមួយ ឬបណ្តឹងទាមទារសំណងដទៃទៀត ក្នុងករណីមានការបាត់បង់ ឬការខូចខាតកើតឡើងដោយផ្ទាល់ ឬប្រយោលពី ឬជាលទ្ធផលបណ្តាលមកពី ឬជាប់ពាក់ពន្ធ័ជាមួយ ឬក្នុងមធ្យោបាយណាមួយក៏ដោយដែលជាប់ទាក់ទងនឹងរូបធាតុដែលដុតមិនឆេះ ឬសម្ភារដទៃទៀតដែលមានសារធាតុដុតមិនឆេះ និងធន់នឹងប្រតិកម្មគីមី ទោះបីជាក្នុងបរិមាណ និងទម្រង់អ្វីក៏ដោយ ។

## លក្ខខណ្ឌទូទៅ_អនុវត្តចំពោះគ្រប់ផ្នែកទាំងអស់

១. លក្ខខណ្ឌជាមុនចំពោះការទទួលខុសត្រូវ

ក) ដោយមិនមានការហាមឃាត់ដោយច្បាប់ បុគ្គលដែលត្រូវបានធានារ៉ាប់រងគ្រប់ពេលវេលាត្រូវប្រតិបត្តិតាម, បំពេញនូវលក្ខខណ្ឌដែលមានក្នុងកិច្ចសន្យានេះ ។

ខ) សច្ចភាពដែលមានបង្ហាញនៅក្នុងសេចក្តីថ្លែងការណ៍ និងចម្លើយនៅក្នុងទំរង់បែបបទស្នើសុំការធានារ៉ាប់រង នឹងក្លាយជាមូលដ្ឋានគ្រឹះនៃកិច្ចសន្យានេះ។

គ) ផ្អែកតាមកិច្ចសន្យាធានារ៉ាប់រងនេះ រាល់ការជូនដំណឹង ឬទំនាក់ទំនងត្រូវបានផ្តល់ ឬធ្វើឡើងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុន ។

២. ការផ្តល់ព័ត៌មានមិនបានគ្រប់ជ្រុងជ្រោយ

ប្រសិនបើមានការខកខានក្នុងការផ្តល់ព័ត៌មានពិតជាក់ស្តែងចំពោះអាជីវកម្ម ឬបរិវេណអគារដែលស្ថិតក្រោមការធានារ៉ាប់រងនេះ ឬការខកខានក្នុងការផ្តល់ព័ត៌មានណាមួយចំពោះការពិតជាក់ស្តែងដែលបានដឹង សម្រាប់ការប៉ាន់ស្មាននូវហានិភ័យ ឬការភ្លេចភ្លាំងណាមួយចំពោះការបង្ហាញនូវការពិតជាក់ស្តែង នោះក្រុមហ៊ុននឹងមិនទទួលខុសត្រូវឡើយដោយផ្អែកតាមកិច្ចសន្យានេះ ។

៣. ការបកស្រាយ

កិច្ចសន្យាធានារ៉ាប់រងនេះ និងតារាងឧបសម្ព័ន្ធ (ដែលជាទម្រង់ទាំងមូលនៃកិច្ចសន្យាធានារ៉ាប់រង) នឹងត្រូវអានជាមួយគ្នាជាកិច្ចសន្យាតែមួយ ហើយចំពោះពាក្យពេចន៍ និងឃ្លាឃ្លោងដែលមានអត្ថន័យជាក់លាក់ដែលបានភ្ជាប់មកជាមួយ នឹងត្រូវមានអត្ថន័យជាក់លាក់បែបនោះ ទោះបីជាស្ថិតនៅ ទីណាក៏ដោយ ។

៤. ការប្រុងប្រយ័ត្ន ឬវិធានការការពារ

បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវចាត់វិធានការការពារយ៉ាងសមហេតុផល ដើម្បីជៀសវាង និងកាត់បន្ថយរបួសលើរាងកាយ, ការបាត់បង់ ឬការខូចខាត និងអនុវត្តបទបញ្ញត្តិជាចាំបាច់ដែលតម្រូវដោយច្បាប់ ឬការដាក់អោយអនុវត្តបទបញ្ជាដោយអជ្ញាធរសាធារណៈណាមួយ ដើម្បីសុវត្ថិភាពបុគ្គល ឬទ្រព្យសម្បត្តិ ។

៥. ការប្រតិបត្តិតាមលក្ខខណ្ឌ និងខចែង

ដោយផ្អែកតាមការប្រតិបត្តិ និងការអនុវត្តតាមលក្ខខណ្ឌទាំងនោះ និងច្បាប់ដែលអាចអនុវត្តបាន ព្រមទាំងខចែងផ្សេងៗទៀតនៃកិច្ចសន្យានេះដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង គឺជាបុរេលក្ខខណ្ឌចំពោះការទទួលខុសត្រូវណាមួយរបស់ក្រុមហ៊ុនក្នុងការធ្វើសំណងដោយផ្អែកតាមកិច្ចសន្យានេះ។

៦. ការផ្តល់ព័ត៌មាន

ក) កាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន

មុនពេលឈានដល់ការធ្វើកិច្ចសន្យា បុគ្គលដែលត្រូវបានធានារ៉ាប់រងមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានដល់ក្រុមហ៊ុន នូវបញ្ហាទាំងឡាយដែល

បានដឹង ឬព័ត៌មានទាំងឡាយដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងគួរតែដឹង ដែលព័ត៌មានទាំងនោះពាក់ព័ន្ធនឹងការធ្វើសេចក្ដីសម្រេចចិត្តរបស់ក្រុមហ៊ុន ក្នុងការទទួលយកនូវហានិភ័យ និងការធ្វើកិច្ចសន្យាធានារ៉ាប់រងនេះដោយផ្អែកលើខចែងអ្វីខ្លះ ។

បុគ្គលដែលត្រូវបានធានារ៉ាប់រងមានកាតព្វកិច្ចដូចគ្នាដែរក្នុងការផ្ដល់ព័ត៌មានទាំងនោះជូនក្រុមហ៊ុន មុនពេលពេលចាប់ផ្ដើមបន្តនូវកិច្ចសន្យាថ្មី, ការធានារ៉ាប់រងបន្ថែម, បដិលេខ ឬការធ្វើកិច្ចសន្យានេះឡើងវិញ ។

ខ) ការលាក់បាំងនូវព័ត៌មាន

ប្រសិនបើបុគ្គលដែលត្រូវបានធានារ៉ាប់រង ខកខានក្នុងការបំពេញកាតព្វកិច្ចផ្ដល់ព័ត៌មាន ក្រុមហ៊ុនអាចធ្វើការបដិសេធរាល់បណ្ដឹងទាមទារសំណងដោយផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ឬមោឃភាពកិច្ចសន្យាធានារ៉ាប់រងនេះតែម្ដង។ ប្រសិនបើការលាក់បាំងនូវព័ត៌មានគឺជាការបន្លំនោះក្រុមហ៊ុនអាចធ្វើមោឃភាពនៃកិច្ចសន្យានេះចាប់តាំងពីថ្ងៃចាប់ផ្ដើមមានសុពលភាព ។

៧. មោឃភាពនៃកិច្ចសន្យា

ក្រុមហ៊ុនអាចធ្វើមោឃភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ តាមរយៈលិខិតអនុសិដ្ឋក្នុងរយៈពេល ១០ថ្ងៃ ទៅកាន់អាស័យដ្ឋានដែលគេស្គាល់ចុងក្រោយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយក្នុងករណីនេះក្រុមហ៊ុននឹងបង់ជូនវិញ នូវបុព្វលាភធានារ៉ាប់រងចំនួន ៩០% នៃបុព្វលាភទាំងអស់ដែលបានបង់ដកចំនួនបុព្វលាភជាក់ស្ដែងសម្រាប់រយៈពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមានសុពលភាព ដោយផ្អែកលើបុព្វលាភអប្បរមាចំនួន ៥២.៥០ ដុល្លារ ដែលបង់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

កិច្ចសន្យាធានារ៉ាប់រងនេះ អាចត្រូវបានបញ្ចប់នៅពេលណាមួយដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ មកក្រុមហ៊ុន និងដោយហេតុថា គ្មានបណ្ដឹងទាមទារសំណងកើតឡើងក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងនេះមានសុពលភាព នោះបុគ្គលដែលត្រូវបានធានារ៉ាប់រងមានសិទ្ធិទទួលបានមកវិញនូវបុព្វលាភធានារ៉ាប់រង ដោយផ្អែកលើបុព្វលាភអប្បរមាដែលបានបង់ចំនួន ៥២.៥០ ដុល្លារ និងដោយផ្អែកលើការកែប្រែបុព្វលាភធានារ៉ាប់រងណាមួយដែលតម្រូវដោយលក្ខខណ្ឌ ឬខចែងនៃកិច្ចសន្យាធានារ៉ាប់រងនេះ ។

៨. នីតិវិធីក្នុងការដោះស្រាយសំណង

លុះត្រាតែមានការបញ្ជាក់ជាពិសេសនៅក្នុងផ្នែកនីមួយៗ ក្នុងករណីមានការបាត់បង់ ឬការខូចខាតណាមួយ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់មកក្រុមហ៊ុនក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីមានការបាត់បង់ ឬការខូចខាតកើតឡើង ឬរយៈពេលលើសពី ១៥ថ្ងៃ ដែលក្រុមហ៊ុនអាចអនុញ្ញាតតម្រូវអោយសរសេរជាលាយលក្ខណ៍អក្សរ និងផ្ញើរជូនមកក្រុមហ៊ុននូវឯកសារដូចខាងក្រោម :

ក) បណ្ដឹងទាមទារសំណងជាលាយលក្ខណ៍អក្សរចំពោះការបាត់បង់ ឬការខូចខាតដោយមានបញ្ជាក់ពីចំនួនច្បាស់លាស់តាមតែអាចធ្វើបាន និងដោយសមហេតុផលនៃតារាង ឬបញ្ជីនៃទ្រព្យសម្បត្តិដែលបានខូចខាត ឬបំផ្លាញ និងចំនួនទឹកប្រាក់ដែលបាត់បង់ ឬខូចខាតដោយយោងលើតម្លៃនៃទ្រព្យសម្បត្តិទាំងនោះនៅពេលដែលមានការបាត់បង់ ឬការខូចខាតកើតឡើងដោយមិនរាប់បញ្ចូលនូវអត្ថប្រយោជន៍គ្រប់ប្រភេទ ។

ខ) កិច្ចសន្យាធានារ៉ាប់រងផ្សេងទៀតប្រសិនបើមាន

បុគ្គលដែលត្រូវបានធានារ៉ាប់រងគ្រប់ពេលវេលាទាំងអស់ក្រោមការចំណាយរបស់ខ្លួន ត្រូវបង្កើត និងផ្ដល់ជូនដល់ក្រុមហ៊ុននូវឯកសារពិស្ដារដទៃទៀតដូចជា : ប្លង់, សេចក្ដីបញ្ជាក់ផ្សេងៗ, សៀវភៅ, សំបុត្របញ្ជាក់, វិក្ក័យប័ត្រ, ច្បាប់ចតចម្លង ឬសំណៅផ្សេងៗ, ឯកសារពាក់ព័ន្ធផ្សេងៗ, ភស្តុតាង និងព័ត៌មានដែលជាប់ទាក់ទងនឹងបណ្ដឹងទាមទារសំណង ព្រមទាំងដើមហេតុ និងមូលហេតុនៃអគ្គិភ័យ និងស្ថានភាពផ្សេងទៀតដែលការបាត់បង់ ឬការខូចខាតបានកើតឡើង និងបញ្ហាណាមួយទាក់ទងនឹងការទទួលខុសត្រូវ ឬចំនួនទឹកប្រាក់ដែលត្រូវទទួលខុសត្រូវរបស់ក្រុមហ៊ុនដែលអាចតម្រូវអោយមានដោយសមហេតុផលដោយ ឬក្នុងនាមក្រុមហ៊ុន ព្រមទាំងសម្បថអះអាង ឬក្នុងទម្រង់ផ្លូវច្បាប់ផ្សេងៗទៀតនៃការប្រកាសការពិតលើបណ្ដឹងទាមទារសំណង និងបញ្ហាពាក់ព័ន្ធដទៃទៀតដែលមាន ។

៩. បណ្ដឹងទាមទារសំណងដែលមានលក្ខណៈក្លែងបន្លំ

ប្រសិនបើការទាមទារសំណងត្រូវបានធ្វើឡើងដោយក្លែងបន្លំ ឬប្រសិនបើការប្រកាសអះអាងខុសពីការពិតត្រូវបានធ្វើឡើង ឬប្រើប្រាស់ដើម្បីគាំទ្រដល់ការទាមទារសំណងនេះ ឬប្រសិនបើមធ្យោបាយ ឬឧបករណ៍ក្លែងបន្លំត្រូវបានប្រើប្រាស់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬដោយនរណាម្នាក់ដែលតំណាងអោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ដើម្បីទទួលបាននូវអត្ថប្រយោជន៍ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ឬប្រសិនបើការបាត់បង់ ឬការខូចខាតត្រូវបានបង្កឡើងដោយសកម្មភាពចេតនា ឬដោយមានការផ្សំគំនិតពីបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬប្រសិនបើការទាមទារសំណងត្រូវបានធ្វើឡើងនឹងបដិសេធ ហើយវិធានការ ឬការប្ដឹងមិនត្រូវបានចាប់ផ្ដើមក្នុងរយៈពេលបី (៣)ខែ ក្រោយពេលជំទាស់ រាល់អត្ថប្រយោជន៍ទាំងអស់ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះត្រូវចាត់ទុកជាអសារបង់ ។

១០. ការចូលរួមចំណែកធ្វើសំណង

ប្រសិនបើនៅពេលបាត់បង់ ឬខូចខាតដែលកើតឡើងចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង មានការធានារ៉ាប់រងផ្សេងទៀត ទោះបីជាទទួលផលប៉ះពាល់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬដោយបុគ្គលផ្សេងទៀតក៏ដោយ ដែលគ្របដណ្ដប់លើទ្រព្យសម្បត្តិដូចគ្នានេះ នោះក្រុមហ៊ុននឹង

មិនទទួលខុសត្រូវក្នុងការបង់ ឬចូលរួមចំណែកច្រើនជាងសមាមាត្រនៃការបាត់បង់ ឬការខូចខាតនោះទេ ។

១១. មជ្ឈត្តការ

ប្រសិនបើមានវិវាទកើតឡើងទាក់ទងនឹងចំនួនទឹកប្រាក់ដែលត្រូវធ្វើសំណងស្ថិតក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ (ការទទួលខុសត្រូវ ត្រូវបានទទួលស្គាល់) វិវាទនោះត្រូវបានបញ្ជូនទៅធ្វើការដោះស្រាយដោយមជ្ឈករម្នាក់ដែលត្រូវបានតែងតាំងដោយអនុលោមតាមលក្ខន្តិកៈ ដែលមានស្រាប់ក្នុងនាមគូនៃវិវាទ សម្រាប់រយៈពេលដែលនៅមានសុពលភាព ។ តាមរយៈលក្ខខណ្ឌនេះ នៅពេលដែលមានវិវាទណាមួយកើតឡើង ត្រូវបញ្ជូនទៅធ្វើមជ្ឈត្តវិនិច្ឆ័យហើយការធ្វើសេចក្តីសម្រេចចិត្តរបស់មជ្ឈត្តករ គឺជាបុរេលក្ខខណ្ឌចំពោះសិទ្ធិប្តឹងជំទាស់នឹងក្រុមហ៊ុន ។

១២. ការទទួលខុសត្រូវរបស់ក្រុមហ៊ុន

គ្មានករណីណាមួយដែលក្រុមហ៊ុនត្រូវទទួលខុសត្រូវសម្រាប់ការបាត់បង់ ឬការខូចខាតបន្ទាប់ពីកិច្ចសន្យានេះផុតកំណត់ក្នុងរយៈពេល ១២ខែ បន្ទាប់ពីថ្ងៃកើតហេតុ លើកលែងតែបណ្តឹងទាមទារសំណងនោះគឺជាករណីរង់ចាំមជ្ឈត្តការ ឬការអនុវត្តច្បាប់ ។

១៣. ការផ្ទេរសិទ្ធិនៃកិច្ចសន្យាធានារ៉ាប់រង

កិច្ចសន្យាធានារ៉ាប់រងនេះមិនអាចធ្វើការផ្លាស់ប្តូរពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានឡើយ ហើយក្រុមហ៊ុននឹងមិនរងផលប៉ះពាល់តាមរយៈការជូនដំណឹងអំពីការចោទប្រកាន់ណាមួយដែលទាក់ទងនឹងការផ្ទេរសិទ្ធិយកទ្រព្យសម្បត្តិរបស់កូនបំណុល ឬបញ្ញាដទៃទៀត ដែលជាប់ទាក់ទងនឹងកិច្ចសន្យានេះ ។

១៤. លក្ខខណ្ឌផ្សេងទៀត

ក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ កិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានចាត់ទុកជាមោឃៈ ទាក់ទងនឹងទ្រព្យសម្បត្តិដែលទទួលរងការខូចខាត លើកលែងតែមុនពេលដែលកើតឡើងនូវការបាត់បង់ ឬការខូចខាតណាមួយ បុគ្គលដែលត្រូវបានធានារ៉ាប់រងបានទទួលនូវការយល់ព្រមជាមុនពីក្រុមហ៊ុនតាមរយៈបដិលេខបំពេញបន្ថែមលើកិច្ចសន្យាធានារ៉ាប់រងនេះដោយ ឬក្នុងនាមក្រុមហ៊ុន

ក) ប្រសិនបើអាជីវកម្ម ឬផលិតកម្មត្រូវបានផ្លាស់ប្តូរ ឬប្រសិនបើប្រភេទនៃអាជីវកម្ម ឬស្ថានភាពដទៃទៀតធ្វើអោយប៉ះពាល់ដល់អគារដែលត្រូវបានធានារ៉ាប់រង ដែលមានទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងនៅក្នុងអគារនោះ ត្រូវបានផ្លាស់ប្តូរ ដែលការផ្លាស់ប្តូរនោះជាការបង្កើននូវហានិភ័យនៃការបាត់បង់ ឬការខូចខាតដោយសារអគ្គិភ័យ ។

ខ) ប្រសិនបើអគារដែលមានទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ត្រូវទុកទំនេរចោលលើសពីរយៈពេល ៣០ថ្ងៃ ។

គ) ប្រសិនបើទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងត្រូវបានផ្លាស់ប្តូរទីតាំងពីអគារណាមួយ ឬពីទីកន្លែងដទៃទៀតខុសពីទីតាំងដែលបានបញ្ជាក់នៅក្នុងតារាងឧបសម្ពន្ធ ។

ឃ) ប្រសិនបើអ្នកទទួលផលប្រយោជន៍ពីទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ត្រូវបានផ្ទេរពីបុគ្គលដែលត្រូវបានធានារ៉ាប់រងដែលធ្វើឡើងមិនស្ថិតក្រោមឆន្ទៈ ឬការប្រតិបត្តិនៃច្បាប់ ។

១៥. លក្ខខណ្ឌអំពីតម្លៃនៃការផ្លាស់ប្តូរ ឬការធ្វើអោយដូចដើមវិញ (មិនអនុវត្តចំពោះសន្ទិធិ)

វាគឺជាការប្រកាសអះអាង និងព្រមព្រៀងគ្នាថា ក្នុងករណីទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងស្ថិតក្រោមកិច្ចសន្យានេះ ត្រូវបានបាត់បង់ ឬខូចខាតមូលដ្ឋានគ្រឹះក្នុងការកំណត់អំពីចំនួនទឹកប្រាក់ដែលត្រូវធ្វើសំណង នឹងត្រូវបានគណនាហើយជាថ្លៃនៃការផ្លាស់ប្តូរ ឬការធ្វើអោយដូចដើមវិញនូវទ្រព្យសម្បត្តិដែលមានប្រភេទ ឬបែបផែនដូចគ្នា ប៉ុន្តែមិនត្រូវលើស ឬមានទំហំធំជាងទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងមាននៅមុនពេលមានការខូចខាត ឬការបាត់បង់ដោយហេតុថាការទទួលខុសត្រូវរបស់ក្រុមហ៊ុន នឹងមិនត្រូវលើសពីចំនួនទឹកប្រាក់សរុបដែលត្រូវបានធានារ៉ាប់រងនៅក្នុងអំឡុងពេលណាមួយនៃការធានារ៉ាប់រងឡើយ ។

ប្រសិនបើនៅពេលដែលមានការផ្លាស់ប្តូរ ឬធ្វើអោយដូចដើមវិញ ចំនួនទឹកប្រាក់ដែលតំណាងអោយតម្លៃដែលត្រូវបានធានារ៉ាប់រងក្នុងលក្ខខណ្ឌ ផ្លាស់ប្តូរ ឬការធ្វើអោយដូចដើមវិញនៃទ្រព្យសម្បត្តិទាំងអស់ដែលត្រូវបានធានារ៉ាប់រង ត្រូវបានបាត់បង់ ឬខូចខាតលើសពីទំហំទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងក្នុងខណៈពេលដែលមានការបាត់បង់ ឬការខូចខាតកើតឡើង នោះបុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវបានចាត់ទុកថា ជាអ្នកធានារ៉ាប់រងដោយខ្លួនឯងផ្ទាល់សម្រាប់ភាពខុសគ្នានោះ និងត្រូវទទួលខុសត្រូវសម្រាប់អត្រាសមាមាត្រនៃការបាត់បង់ ។ ផ្នែកនីមួយៗនៃកិច្ចសន្យាធានារ៉ាប់រងត្រូវអនុវត្តនូវលក្ខខណ្ឌនេះដាច់ដោយឡែកពីគ្នាដោយផ្អែកលើបុរេលក្ខខណ្ឌដូចខាងក្រោម ។

គ្មានការធ្វើសំណងណាមួយ ដែលលើសពីចំនួនទឹកប្រាក់ដែលនឹងត្រូវសងស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះឡើយ ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានអនុវត្ត និងប្រសិនបើក្នុងខណៈពេលនៃការខូចខាត ឬការបំផ្លាញនូវទ្រព្យសម្បត្តិណាមួយដែលត្រូវបានធានារ៉ាប់រង ហើយទ្រព្យសម្បត្តិទាំងនោះត្រូវបានធានារ៉ាប់រងដោយកិច្ចសន្យាធានារ៉ាប់រងផ្សេងទៀតដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលមិនមានមូលដ្ឋានដូចគ្នាក្នុងការធ្វើអោយដូចដើមវិញដូចដែលបានបញ្ជាក់ខាងលើនេះ ។

លក្ខខណ្ឌនេះនឹងមិនត្រូវបានអនុវត្ត ឬមិនមានប្រសិទ្ធិភាពសម្រាប់ផ្នែកទី១ (ក) -អគ្គិភ័យ និងហានិភ័យផ្សេងៗប្រសិនបើ :

ក) បុគ្គលដែលត្រូវបាធានារ៉ាប់រងមិនសហការជាមួយក្រុមហ៊ុនក្នុងរយៈពេល ៦ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការខូចខាត ឬការបំផ្លាញ ឬពេលវេលាលើសពី ៦ខែ តាមតែក្រុមហ៊ុនអាចអនុញ្ញាតជាលាយលក្ខណ៍អក្សរក្នុងគោលបំណងដើម្បីផ្លាស់ប្តូរ ឬធ្វើអោយដូចដើមវិញនូវទ្រព្យសម្បត្តិដែលបានបំផ្លាញ ឬខូចខាត ។

ខ) បុគ្គលដែលត្រូវបានធានារ៉ាប់រងអសមត្ថភាព ឬគ្មានឆន្ទៈដើម្បីផ្លាស់ប្តូរ ឬធ្វើអោយដូចដើមវិញចំពោះទ្រព្យសម្បត្តិដែលបានបំផ្លាញ ឬខូចខាតនៅលើទីតាំងដដែល ឬទីតាំងផ្សេងទៀត ។

១៦. លក្ខខណ្ឌបុព្វលាភធានារ៉ាប់រង

លក្ខខណ្ឌសំខាន់បំផុត និងដាច់ខាតនៃកិច្ចសន្យាធានារ៉ាប់រងនេះ គឺប្រាក់បុព្វលាភដែលដល់ពេលកំណត់ត្រូវបង់ និងទទួលដោយក្រុមហ៊ុនយើងខ្ញុំនៅក្នុងរយៈពេលសាមសិបថ្ងៃ (៣០) គិតចាប់ថ្ងៃចាប់ផ្តើមនៃកិច្ចសន្យាធានារ៉ាប់រង/បដិលេខ/បន្តវិញ្ញាបនប័ត្រធានារ៉ាប់រងថ្មីនេះ ។

ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពទេ កិច្ចសន្យានេះត្រូវចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនយើងខ្ញុំមានសិទ្ធិទទួលបានភាគនៃបុព្វលាភសំរាប់រយៈពេលដែលក្រុមហ៊ុនស្ថិតនៅក្នុងហានិភ័យ ។

នៅពេលដែលបុព្វលាភដែលត្រូវបង់ស្របតាមការធានានេះ ត្រូវបានទទួលដោយភ្នាក់ងារដែលទទួលការអនុញ្ញាតរបស់ក្រុមហ៊ុនយើងខ្ញុំ ការបង់បុព្វលាភនេះត្រូវបានចាត់ទុកថាត្រូវបានទទួលដោយក្រុមហ៊ុនយើងខ្ញុំ សម្រាប់គោលដៅនៃការធានានេះ ហើយក្រុមហ៊ុនយើងខ្ញុំមានបន្ទុកក្នុងការបង្ហាញភស្តុតាងផ្ទុយថា បុព្វលាភនេះត្រូវបានទទួលដោយបុគ្គលមួយរូប រាប់បញ្ចូលទាំងភ្នាក់ងារធានារ៉ាប់រងផងដែរ ដែលពុំត្រូវបានអនុញ្ញាតអោយទទួលបុព្វលាភនេះ ។

រាល់លក្ខខណ្ឌ និងខចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ។

១៧, ខ ចែងស្តីអំពីការដាក់កំហិតទណ្ឌកម្ម និងករណីលើកលែង (LMA 3100)

គ្មានក្រុមហ៊ុនធានារ៉ាប់រងណាមួយ អាចផ្តល់ការធានារ៉ាប់រង និងទទួលខុសត្រូវចំពោះការផ្តល់ប្រាក់សំណងណាមួយ ឬផ្តល់អត្ថប្រយោជន៍ណាមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះបានឡើយ ដែលការផ្តល់ប្រាក់សំណង ឬអត្ថប្រយោជន៍ទាំងនោះធ្វើអោយ ក្រុមហ៊ុនធានារ៉ាប់រងប្រឈមមុខនឹងការដាក់ទណ្ឌកម្មណាមួយ ការហាមឃាត់ ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬ និយតកម្មរបស់សហគមន៍អឺរ៉ុប ចក្រភពអង់គ្លេស ឬ សហរដ្ឋអាមេរិក ។

យើងខ្ញុំសូមរំលឹកលោកអ្នកថា លោកអ្នកត្រូវបង្ហាញដោយភាពស្មោះត្រង់នូវព័តិមានពិតប្រាកដដែលលោកអ្នកដឹង ឬគួរតែដឹង បើមិនដូច្នោះទេលោកអ្នកអាចនឹងមិនទទួលបាននូវអត្ថប្រយោជន៍ណាមួយពីកិច្ចសន្យាធានារ៉ាប់រងរបស់លោកអ្នកឡើយ ។

ទំព័រនេះត្រូវបានទុកចោលដោយចេតនា